សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងដោយឈើឆ្កាល

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ប៉ែន សុភារៈ**
លោក **ស៊ឹម ពិសិទ្ធ**

សាស្ត្រាចារ្យណែនាំ
លោក **ញឹក ឧុធ្លី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

## លោកឪពុក និងអ្នកម្តាយ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុតស្មើនឹងជីវិតកូន

ជាបឋមខ្ញុំបាទឈ្មោះ **ប៉ន សុភារៈ** និងខ្ញុំបាទឈ្មោះ **ស៊ឹម ពិសិទ្ធ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី១៩ ឆ្នាំសិក្សា ២០១៥-២០១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**សូមគោរពប្រតិបត្តិ និងថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖**

-**ប៉ន សុភារៈ** លោកឪពុក **ប៉ន ស៊ាងហ៊ី** -**ស៊ឹម ពិសិទ្ធ** លោកឪពុក **អ៊ុំ សាញ់**

អ្នកម្តាយ **លន់ លក្ខិណា** អ្នកម្តាយ **មៀន សំអូន**

ឆ្លៀតឱកាសដ៏មានតម្លៃនេះ កូនសូមលំឪនកាយសម្តែងនូវការគោរពប្រតិបត្តិ និងកតញ្ញូតាធមិយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនចំពោះលោកអ្នកមានគុណទាំងពីររបស់កូន។ ពិតណាស់លោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់នូវសេចក្តីស្រលាញ់ មេត្តា ករុណា អប់រំទូន្មានឲ្យកូនមាននូវសេចក្តីព្យាយាម អំណត់ ក្លាហាន ព្រមទាំងធ្វើពលិកម្មគ្រប់បែបយ៉ាង ទាំងស្មារតី ទាំងសម្ភារៈក្នុងការសិក្សាតាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រ ដែលជាហេតុធ្វើឲ្យកូនទទួលបាននូវចំណេះដឹងដ៏ថ្លៃថ្នូរ និងភាពជោគជ័យដូចសព្វថ្ងៃនេះ។

កូននៅចងចាំមិនភ្លេចពីគុណយ៉ាងជ្រាលជ្រៅ និងរកអ្វីមកប្រៀបផ្ទឹមឲ្យស្មើពុំបាននូវគុណូបការដ៏ធំធេងរបស់អ្នកមានគុណទាំងពីរ។ កូនសូមលើកដៃទាំងគូឡើង ដើម្បីបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោកយើងនេះ សូមមេត្តាតាមជួយបីបាច់ ថែរក្សាលោកអ្នកមានគុណទាំងពីរឲ្យជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ និងមានជីវិតយឺនយូរ ដើម្បីគង់ជាម្លប់ដ៏សែនត្រជាក់សម្រាប់ជីវិតកូនដ៏យូរអង្វែងតទៅអនាគត។ យើងខ្ញុំក៏មិនភ្លេចដែរ នូវការដឹងគុណដ៏ធំធេងចំពោះ ឯកឧត្តមលោកជំទាវសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ និងបុគ្គលិកនៅការិយាល័យសិក្សាទាំងអស់ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំ គ្រប់គ្រង ជួយជ្រោមជ្រែង និងបង្ហាត់បង្ហាញយើងខ្ញុំឲ្យមានភាពជោគជ័យដូចថ្ងៃនេះ។

ពិសេសនោះ យើងខ្ញុំសូមគោរពដឹងគុណចំពោះលោកសាស្ត្រាចារ្យ **ញឹក ឧត្តី** ដែលបានខិតខំយកចិត្តទុកដាក់ពន្យល់ ណែនាំ បង្ហាត់បង្រៀន និងផ្តល់យោបល់ល្អដល់យើងខ្ញុំបាទក្នុងការចងក្រងសារណាបញ្ចប់ការសិក្សានេះឡើង។

**ជាទីបញ្ចប់** យើងខ្ញុំសូមលំឱនកាយវាចារចិត្ត បួងសួងដល់ទេវតា និងវត្ថុស័ក្តិសិទ្ធិទាំងឡាយ សូមឲ្យអ្នកមានគុណទាំងអស់ ជួបតែពុទ្ធពរទាំងប្រាំប្រការ គឺ **អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំបាទជានិស្សិតនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ផ្នែកនីតិសាស្ត្រ មានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ដែលមានឱកាសក្នុងការសរសេរសារណាបញ្ចប់ការសិក្សានៅក្រោមប្រធានបទ "**ការគ្រប់គ្រងដោយឈីឆ្នាល**" ក្នុងគោលបំណង គឺចង់ពង្រីកការយល់ដឹងពីការគ្រប់គ្រងរបស់បុគ្គលដែលគ្មានសិទ្ធិអំណាចឡើយ។

ក្រោយពីបានឆ្លងកាត់ការសិក្សាអស់រយៈពេល បួនឆ្នាំ ហើយដើម្បីឈានទៅដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ យើងខ្ញុំត្រូវបំពេញនូវលក្ខខណ្ឌមួយទៀត ដែលជាលក្ខខណ្ឌចាំបាច់ផងដែរ នោះគឺការសរសេរសារណាបញ្ចប់ការសិក្សា។ ហេតុនេះហើយ ទើបយើងខ្ញុំទាំងពីរនាក់បានធ្វើការសម្រេចចិត្តរួមគ្នា ក្នុងការជ្រើសរើសប្រធានបទ "ការគ្រប់គ្រងដោយឈីឆ្នាល" ដើម្បីសរសេរសារណាបញ្ចប់ការសិក្សា ហើយយើងខ្ញុំក៏មាននូវគោលបំណងផងដែរ គឺចង់វាស់ស្ទង់នូវចំណេះដឹងក្នុងរយៈពេលបួនឆ្នាំ ដែលយើងខ្ញុំខិតខំសិក្សារៀនសូត្រកន្លងមក។

មុននឹងទទួលបានលទ្ធផលនៃការចងក្រងជាប្រធានបទនេះឡើង យើងខ្ញុំបានខិតខំស្វែងរកគ្រប់ឯកសារដែលមានការពាក់ព័ន្ធជាមួយប្រធានបទនេះ។ តាមរយៈនៃការស្វែងរកនូវឯកសារនេះ ចំណុចដែលគួរកត់សំគាល់ គឺកង្វះខាតនូវឯកសារជាច្រើន ដែលមានការពាក់ព័ន្ធជាមួយប្រធានបទនេះ។ ខ្ញុំសង្ឃឹមថា សារណាដែលយើងខ្ញុំបានចងក្រងឡើង និងមានភាពល្អត្រឹមត្រូវ ប៉ុន្តែក៏មិនប្រាកដថាឥតខ្ចោះនោះដែរ តែទោះជាយ៉ាងណាក៏ដោយ ក៏ប្រធានបទនេះ មានអត្ថប្រយោជន៍ច្រើនដល់ការសិក្សាស្រាវជ្រាវយកចំណេះដឹង ពីព្រោះថាមុននឹងសម្រេចបាននូវផ្លែផ្កានេះបាន យើងខ្ញុំបានរៀបចំឯកសារជាច្រើន ដើម្បីធ្វើការសិក្សាស្វែងយល់។ បន្ទាប់មកទើបរៀបចំសរសេរចងក្រងឡើងដោយមានការជួយជ្រោមជ្រែងពីសាស្ត្រាចារ្យណែនាំ។

ជាចុងក្រោយ យើងខ្ញុំនៅតែសង្ឃឹមថា សារណានេះ នឹងក្លាយទៅជាឯកសារគ្រឹះសម្រាប់ជាជំនួយក្នុងការសិក្សាស្រាវជ្រាវ និងជាគន្លឹះជួយបំភ្លឺផ្លូវដល់និស្សិតជំនាន់ក្រោយ នឹងប្រជាពលរដ្ឋជាក់ជាមិនខានឡើយ។

ជាទីបញ្ចប់នេះ យើងខ្ញុំទាំងពីរនាក់ រង់ចាំទទួលនូវរាល់ការរិះគន់ក្នុងន័យស្ថាបនាពីបណ្តាលនិស្សិតរួមជំនាន់ទាំងអស់ ក៏ដូចជាប្អូនៗនិស្សិតជំនាន់ក្រោយ ដោយក្តីសោមនស្សរីករាយ និងគោរពរាប់អានដល់ជ្រាលជ្រៅបំផុតអំពីយើងខ្ញុំទាំងពីរនាក់។

# មាតិកា

**ទំព័រ**


**សេចក្ដីផ្ដើម** ........................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការគ្រប់គ្រងដោយឈឺឆ្អាល**

**ផ្នែកទី១៖ បទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធ** ........................................ ៤

**កថាភាគទី១៖ បទដ្ឋានគតិយុត្ត** ........................................ ៤

១.អត្ថន័យតាមក្រមរដ្ឋប្បវេណីចាស់ (ឆ្នាំ១៩២០) ........................................ ៤

២.អត្ថន័យតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ន (ឆ្នាំ២០០៧) ........................................ ៤

**កថាភាគទី២៖ ឯកសារពាក់ព័ន្ធនឹងការគ្រប់គ្រងដោយឈឺឆ្អាល** ........................................ ៥

១.អត្ថន័យតាមពាក្យពេចន៍ ........................................ ៥

២.អត្ថន័យតាមសេចក្ដីផ្ដើមរដ្ឋប្បវេណីជប៉ុន ........................................ ៧

**ផ្នែកទី២៖ លក្ខខណ្ឌបង្កើត និងប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល** ........................................ ៨

**កថាភាគទី១៖ លក្ខខណ្ឌបង្កើតនៃការគ្រប់គ្រងដោយឈឺឆ្អាល** ........................................ ៨

១.លក្ខខណ្ឌទូទៅនៃធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ........................................ ៨

១.១.សមត្ថភាពខាងឆន្ទៈ ........................................ ៨

១.២.សមត្ថភាពក្នុងការធ្វើសកម្មភាព ........................................ ៨

១.៣.សមត្ថភាពអ្នកតំណាងតាមការស្ម័គ្រចិត្ត ........................................ ៨

២.លក្ខខណ្ឌពិសេសនៃការបង្កើតការគ្រប់គ្រងដោយឈឺឆ្អាល ........................................ ៩

២.១.ការគ្រប់គ្រងធ្វើឡើងដោយគ្មានសិទ្ធិអំណាច ........................................ ៩

២.១.១.ភាពគ្មានសិទ្ធិអំណាចតាមច្បាប់ ........................................ ៩

២.១.១.១.ចំពោះបុគ្គល ........................................ ៩

២.១.១.២.ចំពោះទ្រព្យ ........................................ ១០

២.១.២.ភាពគ្មានសិទ្ធិអំណាចតាមកិច្ចសន្យា ........................................ ១០

២.១.២.១.ការមិនបានព្រមព្រៀងគ្នាទុកជាមុនតាមកិច្ចសន្យា ........................................ ១០

២.១.២.២.ភាពគ្មានលក្ខណៈបង្ខិតបង្ខំ ........................................ ១១

២.២.ការគ្រប់គ្រងធ្វើឡើងដើម្បីបុគ្គលដទៃ ........................................ ១១

២.៣.ការគ្រប់គ្រងដើម្បីផលប្រយោជន៍ ............ ១២
២.៤.អ្នកគ្រប់គ្រងចាប់ផ្ដើមគ្រប់គ្រងកិច្ចការ ............ ១៣
២.៥.ការគ្រប់គ្រងធ្វើឡើងដោយវិធីសមរម្យ ឬតាមឆន្ទៈបុគ្គលសាមីខ្លួន ............ ១៤
**កថាភាគទី២៖ ប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល** ............ ១៥
១.ការគ្រប់គ្រងត្រូវធ្វើឡើងចំពោះបុគ្គល និងទ្រព្យ ............ ១៥
១.១.ចំពោះបុគ្គល ............ ១៥
១.២.ចំពោះទ្រព្យសម្បត្តិ ............ ១៥
២.ការគ្រប់គ្រងធ្វើឡើងក្នុងស្ថានភាពភាពបន្ទាន់ ............ ១៥
២.១.ការការពារស្ថានភាពចាំបាច់ ............ ១៥
២.១.១.សកម្មភាពឯកតោភាគី ............ ១៦
២.១.២.សកម្មភាពឆ្លើយតបនឹងការសង្គ្រោះបន្ទាន់ ............ ១៦
២.២.ការគ្រប់គ្រងដោយគ្មានគំនិតទុច្ចរិត ............ ១៦
២.២.១.ការគ្រប់គ្រងដោយគ្មានកំហុស ............ ១៧
២.២.២.ការមិនទទួលខុសត្រូវលើសំណងនៃការខូចខាត ............ ១៧

## ជំពូកទី២

## ករណីយកិច្ចរបស់គូភាគីក្នុងការគ្រប់គ្រងដោយឈឺឆ្អាល

**ផ្នែកទី១ ៖ ករណីយកិច្ចរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល** ............ ១៨
១.ករណីយកិច្ចជូនដំណឹង ............ ១៨
១.១.សាមីខ្លួនបានយល់ព្រមឲ្យអ្នកគ្រប់គ្រងចាប់ផ្ដើមធ្វើការគ្រប់គ្រង ............ ១៩
១.២.សាមីខ្លួនធ្វើការបដិសេធមិនឲ្យចាប់ផ្ដើមការគ្រប់គ្រង ............ ១៩
១.៣.សាមីខ្លួនផ្ដល់ការយល់ព្រមយឺតយ៉ាវ ............ ២០
២.ករណីយកិច្ចបន្តគ្រប់គ្រង ............ ២១
៣.ករណីយកិច្ចប្រគល់កម្មវត្ថុនៃការគ្រប់គ្រងទៅម្ចាស់ទ្រព្យវិញ ............ ២៤
៤.ករណីយកិច្ចរាយការណ៍ ............ ២៤
៥.ករណីយកិច្ចទាមទារសំណងចំពោះប្រាក់ដែលបានចំណាយ ............ ២៥
៦.ករណីយកិច្ចគ្រប់គ្រងដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួន ឬតាមវិធីសមរម្យ ............ ២៥
**ផ្នែកទី២ ៖ ករណីយកិច្ចរបស់អ្នកត្រូវគេគ្រប់គ្រង** ............ ២៦
១.ករណីយកិច្ចប្រគល់សោហ៊ុយលើការគ្រប់គ្រង ............ ២៦

២.ករណីយកិច្ចប្រគល់កម្រៃ ..................................................................................................២៦
៣.ករណីយកិច្ចគិតអត្រាការប្រាក់ចំពោះការយឺតយ៉ាវ ..............................................................២៦

## ជំពូកទី៣

## សិទ្ធិរបស់គូភាគីក្នុងការគ្រប់គ្រងដោយឈឺឆ្អាល

**ផ្នែកទី១ ៖ សិទ្ធិរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល** ......................................................................២៨
**កថាភាគទី១ ៖ សិទ្ធិទាមទារសោហ៊ុយរបស់អ្នកគ្រប់គ្រង** ......................................................២៨
១.សិទ្ធិទាមទាររបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល ឬអាណត្តិគាហក...........................................២៨
២.សិទ្ធិទាមទាការចំណាយបង្កើនតម្លៃ....................................................................................២៨
២.១.សោហ៊ុយចំណាយចាំបាច់...................................................................................២៩
២.២.ការចំណាយសម្រាប់គ្រប់គ្រង និងថែរក្សា ឬចំណាយបង្កើនតម្លៃ ...............................២៩
៣.សិទ្ធិទាមទារត្រឹមតែកម្រឹតដែលប្រយោជន៍ជាក់ស្តែងរបស់សាមីខ្លួន.......................................៣០
**កថាភាគទី២ ៖ សិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រង**............................................................៣០
**ផ្នែកទី២ ៖ សិទ្ធិរបស់អ្នកត្រូវឲ្យគេគ្រប់គ្រងដោយឈឺឆ្អាល** .....................................................៣១
១.សិទ្ធិទាមទារសំណងនៃការខូចខាតមកវិញ ..........................................................................៣១
២.សិទ្ធិបញ្ឈប់សកម្មភាពបន្តការគ្រប់គ្រងដោយឈឺឆ្អាល .........................................................៣១
៣.សិទ្ធិទាមទារអោយមានការរាយការណ៍ពីការគ្រប់គ្រង ..........................................................៣១
**សេចក្តីសន្និដ្ឋាន** ............................................................................................................................៣២
**អនុសាសន៍** ....................................................................................................................................៣៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

មនុស្សគ្រប់រូបមានទំនាក់ទំនងនឹងគ្នាក្នុងការរស់នៅក្នុងសង្គមរៀងៗខ្លួន ហើយការរស់នៅក្នុងសង្គមនេះ ចាំបាច់ត្រូវមានវិធានច្បាប់ ឬក៏បទដ្ឋានគតិយុត្ត សម្រាប់គ្រប់គ្រងសង្គមមួយឲ្យមានសណ្តាប់ធ្នាប់ល្អ សន្តិសុខ និងសេចក្តីរីកចម្រើនក្នុងសង្គមជាតិមួយ។ សង្គមសម័យបុព្វកាល គេគ្រប់គ្រងរដ្ឋត្រូវធ្វើឡើងដោយផ្អែកលើតាមវិធានសាសនា ដែលប្រជាជននៅក្នុងសង្គមនោះរស់នៅដោយគោរពយកវិធាន សាសនា ជាបទដ្ឋានច្បាប់ក្នុងការកាត់ក្តី ឬ ដោះស្រាយនូវបញ្ហាផ្សេងៗ ប៉ុន្តែដោយសារការវិវត្តនៃបច្ចេកវិទ្យា ក៏ដូចជាភាពជឿនលឿនទៅមុខ ធ្វើឲ្យបទដ្ឋាននេះពុំអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងទៅលើបញ្ហាសង្គមដែលបានកើតមានឡើងតទៅទៀត។ ដូច្នេះទើបមនុស្សបង្កើតឲ្យមាននូវច្បាប់ ក៏ដូចជាបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ក្នុងការគ្រប់គ្រងសង្គមឲ្យមានប្រសិទ្ធិភាព តម្លាភាព ចំពោះប្រជាជនក្នុងសង្គម នោះមានន័យថា ការធ្វើឲ្យមានលក្ខណៈចាប់បង្ខំទៅលើការទទួលខុសត្រូវនៅក្នុងសង្គមនីមួយៗ ដោយប្រជាជនទាំងអស់ គឺមានកាតព្វកិច្ចទទួលខុសត្រូវនូវរាល់ទង្វើរបស់ខ្លួន ក៏ដូចជាទង្វើរបស់អ្នកដទៃផងដែរ។

ទន្ទឹមនឹងការបង្កើតឲ្យមាននូវការទទួលខុសត្រូវទៅលើទង្វើ ហើយទង្វើមួយចំនួនជានិច្ចជាកាលដែលយកចិត្តទុកដាក់ចំពោះកិច្ចការរបស់អ្នកដទៃ ទោះបីគ្មានសិទ្ធិអំណាច ឬ ករណីយកិច្ចតាមផ្លូវច្បាប់ក៏ដោយ ក៏គ្មានការទទួលត្រូវផងដែរ។ ប្រសិនបើយើងអនុវត្តគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនឱ្យជាក់លាក់ទៅ ការជួយគ្នាទៅវិញទៅមកបែបនេះ ត្រូវបានវាយតម្លៃថាខុសច្បាប់។ ដោយផ្អែកលើហេតុផលនេះហើយ ជាករណីលើកលែងចំពោះគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាងនាំឲ្យមានសាមគ្គីភាពសង្គម និងកិច្ចសហប្រតិបត្តិការល្អទៅវិញទៅមក ដែលមានសារៈសំខាន់ណាស់នៅក្នុងជីវិតរបស់មនុស្សយើង។ ហេតុនេះហើយបានជាក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក្នុងគន្ថីទី៥ ជំពូកទី១៤ ចែងអំពីការគ្រប់គ្រងដោយឈឺឆ្អាលជាគោលការណ៍មួយបង្កើតឱ្យមាន ការចេះជួយគ្នាទៅវិញទៅមកនៅក្នុងសង្គម។

ដោយមើលឃើញនូវសារៈសំខាន់ និងភាពចាំបាច់ក្នុងការជីវភាពរស់នៅប្រចាំថ្ងៃរបស់ពលរដ្ឋមួយចំនួនដែលទាក់ទងទៅនឹងការឈឺឆ្អាល ឬ ការគ្រប់គ្រងដោយឈឺឆ្អាលនេះហើយ ទើបមានសំនួរមួយចំនួនដែលពាក់ព័ន្ធនឹងចម្ងល់ថា តើអ្វីទៅជាការគ្រប់គ្រងដោយឈឺឆ្អាល? តើមានលក្ខខណ្ឌអ្វីខ្លះ? ដែលចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាល? តើករណីយកិច្ច និងសិទ្ធិរបស់គូភាគីក្នុងការគ្រប់គ្រងដោយឈឺឆ្អាលមានអ្វីខ្លះ?

គោលបំណងនៃកិច្ចការស្រាវជ្រាវលើប្រធានបទនេះ គឺជាការរួមចំណែកមួយក្នុងការអនុវត្តច្បាប់ដែលទាក់ទងទៅនឹងកាតព្វកិច្ចកំណត់ដោយច្បាប់ ជាពិសេស ដើម្បីឲ្យអ្នកអានគ្រប់គ្នាមាននូវចំណេះដឹងបន្ថែមទាក់ទងទៅនឹងប្រធានបទ នៃកិច្ចការស្រាវជ្រាវមួយនេះ គឺសំដៅដល់ការគ្រប់គ្រងដោយឈឺឆ្អាល។ លើសពីនេះទៅទៀត កិច្ចការស្រាវជ្រាវលើប្រធានបទនេះ មានគោលបំណងបង្ហាញពីសញ្ញាណគតិយុត្តនៃការគ្រប់គ្រងដោយឈឺឆ្អាល និងករណីយកិច្ច និងសិទ្ធិរបស់គូភាគីនៃការគ្រប់គ្រងដោយឈឺឆ្អាល។ ម្យ៉ាងវិញទៀត ដើម្បីចៀសវាងពីវិវាទកើតឡើងនៅពេលបញ្ចប់ការគ្រប់គ្រងដោយឈឺឆ្អាល ដែលកើតឡើងដោយការធ្វេសប្រហែស មិនគោរពតាមលក្ខខណ្ឌដែលច្បាប់បានចែង និងដើម្បីការពារនូវផលប្រយោជន៍របស់ជនសុច្ចរិតត្រឹមត្រូវ។

នៅក្នុងកិច្ចការស្រាវជ្រាវនេះ យើងខ្ញុំនឹងធ្វើការបែងចែកជា៣ជំពូកៈ

- **ជំពូកទី១ៈ សញ្ញាណគតិយុត្តនៃការគ្រប់គ្រងដោយឈឺឆ្អាល** សំដៅអំពីអត្ថន័យ លក្ខខណ្ឌ និងប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល។
- **ជំពូកទី២ៈ ករណីយកិច្ចរបស់គូភាគីក្នុងការគ្រប់គ្រងដោយឈឺឆ្អាល** គឺសំដៅទៅដល់កិច្ចការទាំងឡាយដែលត្រូវធ្វើ និងការជូនដំណឹងអំពីហេតុការណ៍ឲ្យគ្នាទៅវិញទៅមក។
- **ជំពូកទី៣ៈ សិទ្ធិរបស់គូភាគីក្នុងការគ្រប់គ្រងដោយឈឺឆ្អាល** គឺសំដៅទៅលើការទាមទារផលប្រយោជន៍ ឬការខូចខាតដែលខ្លួនបានចំណាយ។

ដូចនេះ យើងខ្ញុំនឹងធ្វើការលើកយកមកបង្ហាញ ក៏ដូចជាបកស្រាយលម្អិតទៅតាមជំពូកនីមួយៗនៅក្នុងប្រធានបទសារណានេះ។

# ជំពូកទី១

# សញ្ញាណទូទៅនៃការគ្រប់គ្រងដោយឈឺឆ្អាល

ការគ្រប់គ្រងដោយឈឺឆ្អាល គឺជាកាតព្វកិច្ចមួយប្រភេទ ដែលមានប្រភពមកពីការកំណត់របស់ច្បាប់។ កាតព្វកិច្ចប្រភេទនេះ ហាក់ដូចជាមានលក្ខណៈផ្ទុយពី "គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន" (មាត្រា ៣ នៃក្រមរដ្ឋប្បវេណី) ដែលបានគោរពនូវសេរីភាពនៃឆន្ទៈបុគ្គលឯកជន មានន័យថា កាតព្វកិច្ច ត្រូវបានបង្កើតឡើង តាមឆន្ទៈរបស់បុគ្គលឯកជនផ្ទាល់តែម្តង ឬ អាចនិយាយបានថា "មានឆន្ទៈទើបមានកាតព្វកិច្ច"។ ប៉ុន្តែផ្ទុយមកវិញ ការគ្រប់គ្រងដោយឈឺឆ្អាល ជាកាតព្វកិច្ចមួយដែលមិនបានបង្កើតឡើងតាមរយៈឆន្ទៈរបស់គូភាគីនោះទេ ពោលគឺភាគីណាមួយបានធ្វើកិច្ចការឡើង ដើម្បីប្រយោជន៍ភាគីម្ខាងទៀតដោយច្បាប់បានតម្រូវឱ្យភាគីដែលមានប្រយោជន៍នោះ ត្រូវមានកាតព្វកិច្ចបង់នូវសោហ៊ុយ ព្រមទាំងកម្រៃជូនភាគីដែលបំពេញកិច្ចការនោះ។

មួយវិញទៀត ច្បាប់ចាប់បង្ខំឲ្យអនុវត្តដូចនេះ គឺដើម្បីលើកទឹកចិត្តដល់មនុស្សឲ្យចេះជួយយកអាសារគ្នា ចេះសង្គ្រោះគ្នាទៅវិញទៅមកនៅក្នុងសង្គម ឱ្យសក្តិសមជាពុទ្ធសាសនិកដែលប្រកាន់យកសាសនាព្រះពុទ្ធជាសាសនារបស់រដ្ឋ។ ការបញ្ញត្តិដូចនេះ គឺដើម្បីការពារផលប្រយោជន៍របស់បុគ្គលដែលបានឈឺឆ្អាល កុំឲ្យបាត់បង់ដោយសារតែជួយយកអាសារគេ ពោលគឺអ្នកនោះអាចទទួលយកមកវិញ នូវសំណងនៃការចំណាយរួមទាំងកម្រៃទៀតផង។

គោលគំនិតសំខាន់មួយទៀតដែរនោះគឺថា ការពារបុគ្គលដែលជាអ្នកគ្រប់គ្រង ឲ្យរួចផុតពីការទទួលខុសត្រូវនូវការកាន់កាប់ដោយបំពានទ្រព្យ ឬ គ្រប់គ្រងបុគ្គលផ្សេងដោយបំពាន។ ក្នុងករណីដែលអ្នកគ្រប់គ្រងនោះ ពិតជាមានចេតនាក្នុងការការពារផលប្រយោជន៍នៃទ្រព្យ ឬ អ្នកមានសិទ្ធិលើបុគ្គលប្រាកដមែន។ ម៉្យាងវិញទៀតដែរនេះ ក៏ជាការការពារដល់ជនឆ្លៀតឱកាសមួយចំនួន ដើម្បីទទួលបាននូវការគេចប្រវេញ ឬ តែបំបាត់នូវទ្រព្យសម្បត្តិផ្សេងៗ របស់ម្ចាស់ទ្រព្យ ដោយយកមូលហេតុដោយសារតែការគ្រប់គ្រងដោយឈឺឆ្អាល។ ហេតុផលទាំងនេះ ទើបមានលក្ខខណ្ឌច្បាប់បានកំណត់អំពីការគ្រប់គ្រងដោយឈឺឆ្អាល ដែលបានកំណត់ចំពោះបុគ្គលមួយចំនួន ហើយគ្មានការពឹងពាក់ទុកជាមុន និងគ្មានសិទ្ធិអំណាចចំពោះកិច្ចការទាំងនោះ ប៉ុន្តែជាមូលដ្ឋាន គឺជាការបង្កើតនូវទំនុកចិត្តលើគ្នា ដោយភាពសាមគ្គី ដោយសម្បុរធម៌ សមធម៌ ឲ្យសមជាប្រពលរដ្ឋល្អក្នុងសង្គមចេះជួយគ្នា ទើបមានបញ្ញត្តិច្បាប់នៃការគ្រប់គ្រងដោយឈឺឆ្អាលឡើង ដើម្បីរំលែកទុកលំបាក និងការលើកទឹកចិត្តដំបុគ្គលនានាក្នុងសកម្មជាអំពើល្អរបស់សង្គមជាតិ។

# ផ្នែកទី១ ៖ បទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធ

## កថាភាគទី១ ៖ បទដ្ឋានគតិយុត្តិ

### ១.អត្ថន័យតាមក្រមរដ្ឋប្បវេណីខ្មែរសង្គមចាស់(ឆ្នាំ១៩២០)

មាត្រា ៨២៥ ចែងថា "ជនណាឥតគេពឹងរក ហើយទទួលគ្រប់គ្រងនូវទ្រព្យសម្បត្តិនៃជនដទៃដោយឈឺឆ្អាលពីចិត្តឯង ជននោះត្រូវទទួលការគ្រប់គ្រង លុះត្រាតែម្ចាស់គេមកគ្រប់គ្រងវិញខ្លួនឯងវិញ។ ជននោះត្រូវយកចិត្តទុកដាក់ ចាត់ចែងកិច្ចការហាក់បីដូចជាឪពុក ដ៏ប្រពៃនៃត្រកូល គឺថាទុកខ្លួនឯងដូចម្ចាស់របស់ពិតៗ និងយកចិត្តទុកដាក់ និងផលប្រយោជន៍ទ្រព្យនោះផង។"[1]

យោងតាមមាត្រា ៨២៦ បានចែងថា "កម្មសិទ្ធិករនៃបេតិកភណ្ឌ ដែលគេបានគ្រប់គ្រងឲ្យដោយត្រឹមត្រូវនោះ ត្រូវសងទៅអ្នកដែលគ្រប់គ្រងនោះ នូវប្រាក់ដែលគេបានចេញចាយវាយក្នុងការជាចាំបាច់ ឬក្នុងការមានប្រយោជន៍ទាំងប៉ុន្មាន មួយទៀតគេ និងវិញមួយទៀតជននោះត្រូវគិតសោហ៊ុយនៃសេចក្តីលំបាកក្នុងការថែរក្សានោះឲ្យគេផងទៀត។"[2]

តាមអត្ថន័យខាងលើនេះ យើងអាចធ្វើការទាញនូវសញ្ញាណនៃការគ្រប់គ្រងដោយឈឺឆ្អាលបានដូចខាងក្រោម៖

- គេមិនពឹង ធ្វើដោយចិត្តឯង
- ទ្រព្យសម្បត្តិអ្នកដទៃ
- បញ្ចប់ពេលម្ចាស់គេមកគ្រប់គ្រងវិញ
- គ្រប់គ្រងក្នុងនាមឪពុកដ៏ប្រពៃ
- ដើម្បីប្រយោជន៍អ្នកដទៃ

ការគ្រប់គ្រងដោយឈឺឆ្អាលនៅទីនេះ គឺបានកំណត់យ៉ាងជាក់លាក់ សំដៅទៅលើតែទ្រព្យសម្បត្តិតែប៉ុណ្ណោះ មិនបានអនុវត្តទៅលើបុគ្គលនោះទេ។

### ២.អត្ថន័យតាមក្រមរដ្ឋប្បវេណីបច្ចុប្បន្ន (ឆ្នាំ២០០៧)

តាមមាត្រា ៧២៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានឱ្យនិយមន័យថា "ការគ្រប់គ្រងដោយឈឺឆ្អាល" សំដៅលើការចាប់ផ្តើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ។ តាមអត្ថន័យនៃមាត្រានេះ ការគ្រប់គ្រងដោយឈឺឆ្អាល មិនបានកំណត់

[1] មាត្រា៨២៥ ក្រមរដ្ឋប្បវេណីខ្មែរសង្គមចាស់ឆ្នាំ១៩២០

[2] មាត្រា៨២៦ ក្រមរដ្ឋប្បវេណីខ្មែរសង្គមចាស់ឆ្នាំ១៩២០

ឲ្យច្បាស់លាស់លើអំពី ការគ្រប់គ្រងលើទ្រព្យ ឬ បុគ្គល ដូចនៅក្នុងក្រមរដ្ឋប្បវេណីខ្មែរថ្មីឆ្នាំ ២០០៧ នេះគឺគ្រាន់តែបញ្ញត្តិពីការចាប់ផ្តើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃប៉ុណ្ណោះ ដោយមិនបានកំណត់អំពីការគ្រប់គ្រងទៅលើទ្រព្យសម្បត្តិ ឬបុគ្គលទេ។[3]

ឧទាហរណ៍៖ លោក **ក** បានចេញទៅលេងសៀមរាបចំនួន ០៣ថ្ងៃ ដោយគ្មានអ្នកណានៅចាំផ្ទះទេ។ ខណៈនោះក៏មានភ្លៀង និងខ្យល់ខ្លាំងបានធ្វើឱ្យដំបូលផ្ទះរបស់លោក **ក** ប៉ើងនិងធ្លុះធ្លាយដែលបណ្តាលឱ្យមានភ្លៀងស្រក់លិចចូលក្នុងផ្ទះ។ លោក **ខ** ដែលអ្នកជិតខាងនឹងលោក **ក** បានឃើញដូចនោះ ក៏បានជួលឱ្យជាងទិញសង្កសីដើម្បីជួសជុលផ្ទះឱ្យលោក **ក**។

ករណីនេះ បញ្ជាក់ថា លោក **ខ** គឺធ្វើការគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ក្នុងអំឡុងពេលដែលលោក **ក** មិនបាននៅផ្ទះ។ គោលគំនិតនៃមាត្រានេះ គឺចង់ឲ្យបុគ្គលម្នាក់ៗ ចេះជួយគ្នាវិញទៅមកដោយមិនប្រកាន់វណ្ណៈ ឬរើសអើង និងមិនឲ្យមើលនឹងភ្នែកចំពោះហេតុការណ៍ដែលបានកើតឡើង។

## កថាភាគទី២ ៖ ឯកសារដែលពាក់ព័ន្ធនឹងការគ្រប់គ្រងដោយឃីផ្លាល

### ១.អត្ថន័យតាមពាក្យពេចន៍

ការគ្រប់គ្រងតាមដោយឃីផ្លាល វាមានពីការផ្សំបញ្ចូលគ្នារវាងពាក្យថា "ការគ្រប់គ្រង" និង ពាក្យ "ការឃីផ្លាល"។

- ការគ្រប់គ្រង មានអត្ថន័យដូចខាងក្រោម[4]៖

- ការគ្រប់គ្រង អាចជាការគ្រប់គ្រងមនុស្ស និងការគ្រប់គ្រងលើទ្រព្យ។
- ការគ្រប់គ្រង អាចជាការគ្រប់គ្រងដោយផ្ទាល់ និង ការគ្រប់គ្រងដោយប្រយោល។
- ការគ្រប់គ្រង នាំឱ្យមានការពិចារណា ទៅលើរបៀបនៃការគ្រប់គ្រង ដែលជាគោលការណ៍ការគ្រប់គ្រងត្រូវចាំបាច់នាំឱ្យមានលក្ខណៈល្អប្រសើរ ត្រឹមត្រូវ និង ជាទុកចិត្តបាន។
- ការគ្រប់គ្រង នាំឱ្យមានការទទួលខុសត្រូវលើការគ្រប់គ្រង ករណីមានព្យសនកម្មកើតឡើងដោយសារការគ្រប់គ្រងរបស់អ្នកគ្រប់គ្រង។
- ការគ្រប់គ្រងលើមនុស្ស អាចជាការគ្រប់គ្រងលើបុគ្គលដែលស្ថិតក្នុងបន្ទុកគ្រួសារ និងការគ្រប់គ្រងបុគ្គលិក/មន្ត្រីក្រោមឱវាទ។

---

[3] មាត្រា៧២៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[4] http://bizdoctors.asia/%E1%9E%8F%E1%9E%BE%E1%9E%A2%E1%9F%92%E1%9E%9C%E1%9E%B8%E1%9E%87%E1%9E%B6%E1%9E%80%E1%9E%B6%E1%9E%9A%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%94%E1%9F%8B%E1%9E%82%E1%9F%92%E1%9E%9A%E1%9E%84/

- ការគ្រប់គ្រងលើទ្រព្យ អាចការគ្រប់គ្រងទ្រព្យជាកម្មសិទ្ធិផ្ទាល់ខ្លួន និង ការគ្រប់គ្រងទ្រព្យជាកម្មសិទ្ធិអ្នកដទៃ។
- ការគ្រប់គ្រងទ្រព្យដែលជាកម្មសិទ្ធិអ្នកដទៃ អាចជាការគ្រប់គ្រងតាមរយៈកិច្ចសន្យា និង គ្មានកិច្ចសន្យា។
- ការគ្រប់គ្រង បានបង្កប់នូវការទទួលបាននូវតម្លៃតបស្នង ឬ ផលកម្រៃដែលបានមកពីការគ្រប់គ្រង។
- ការគ្រប់គ្រង នាំឱ្យមានការចំណាយលើការគ្រប់គ្រង ដែលគួរពិចារណាលើបន្ទុកក្នុងការបានចំណាយ។

  - ការឈឺឆ្អាល មានអត្ថន័យដូចខាងក្រោមនេះ[5]៖

- ការឈឺឆ្អាល គឺជាការយកអាសា ជួយធ្វើការដោះទុក្ខធុរៈគេផ្សេងៗ។
- ការឈឺឆ្អាល នាំឱ្យមានការគិតដល់ថា មានកិច្ចការដែលត្រូវបំពេញ ឬ បញ្ហាបាន កើតឡើងដែលមិនមែនជាបញ្ហារបស់ខ្លួន។
- ការឈឺឆ្អាល សំដៅលើបុគ្គលដែលឈឺឆ្អាល មិនមានការទទួលបានសិទ្ធិអំណាចក្នុងការដោះស្រាយពីដំបូង ឬ គ្មានការយល់ព្រមឱ្យដោះស្រាយបញ្ហាជាមុនឡើយ។
- ការឈឺឆ្អាល នាំឱ្យមានការពិចារណាដល់ថា ការបំពេញកិច្ចទាំងឡាយ គឺដើម្បីផលប្រយោជន៍អ្នកដទៃ ដែលមិនមែនជាប្រយោជន៍របស់អ្នកឈឺឆ្អាលនោះទេ។
- ការឈឺឆ្អាល នាំឱ្យមានការដឹងគុណពីអ្នកមានបញ្ហា ឬការមិនសប្បាយចិត្តពីអ្នកមានបញ្ហា។
- ការឈឺឆ្អាល នាំឱ្យមានការបំពេញកិច្ចការណាមួយ ឬច្រើន។

  - ការគ្រប់គ្រងដោយឈឺឆ្អាល នាំឱ្យមានសញ្ញាណមួយចំនួនដូចខាងក្រោម៖

- ការគ្រប់គ្រងដោយឈឺឆ្អាល គឺជាការគ្រប់គ្រងលើមនុស្ស ឬ ទ្រព្យ ដែលស្ថិតនៅក្នុងបន្ទុក ឬ ជាកម្មសិទ្ធិរបស់អ្នកដទៃ។
- ការគ្រប់គ្រងដោយឈឺឆ្អាល គឺជាការគ្រប់គ្រងដោយអ្នកគ្រប់គ្រងដោយឈឺឆ្អាល គ្មានសិទ្ធិអំណាចក្នុងការគ្រប់គ្រង។
- ការគ្រប់គ្រងដោយឈឺឆ្អាល នាំឱ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចមានការចំណាយលើការគ្រប់គ្រង ដែលអ្នកគ្រប់គ្រង អាចនឹងត្រូវទទួលបានត្រលប់មកវិញ។

[5]http://dictionary.tovnah.com/word/%E1%9E%88%E1%9E%BA%E1%9E%86%E1%9F%92%E1%9E%A2%E1%9E%B6%E1%9E%9B

- អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចត្រូវទទួលបានកម្រៃដែលជួយបង្កើនតម្លៃលើទ្រព្យនោះ ដែលបណ្ដាលមកពីការគ្រប់គ្រងរបស់ខ្លួន។
- ការគ្រប់គ្រងដោយឈឺឆ្អាល អាចនាំឱ្យអ្នកគ្រប់គ្រងទទួលខុសត្រូវនូវកំហុសរបស់ខ្លួន។

តាមរយៈការបកស្រាយនូវអត្ថន័យនៃការគ្រប់គ្រងដោយឈឺឆ្អាលខាងលើនេះ ជាបញ្ហាខាងក្រោមនេះ ចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាលដែរ ឬទេះ

តើការគ្រប់គ្រង មនុស្សដែលស្ថិតនៅក្រោមអាណាព្យាបាលអ្នកដទៃ អាចចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាលដែរឬទេ? ឧទាហរណ៍៖ លោក **ក** បានឃើញកូនប្រុសរបស់លោក **ខ** ដែលជាអ្នកជិតខាងរបស់ខ្លួន កំពុងតែឈរយំនៅក្នុងផ្សារមួយ ពេលនោះ លោក **ក** ក៏បាននាំកូនប្រុសទាក់ទងដែរ តែមិនអាចទាក់ទងបានទេ។ លោក **ក** ក៏សម្រេចចិត្តនាំកូនប្រុសលោក **ខ** មកផ្ទះរបស់ខ្លួន។ កូនប្រុសលោក **ខ** ក៏មានជម្ងឺរាគដែរ។ ខណៈនោះលោក **ក** បាននាំកូនប្រុសលោក **ខ** ទៅមន្ទីរពេទ្យដើម្បីព្យាបាលដោយអស់ប្រាក់ចំនួន ៣០០$ និងបានចំណាយលើអាហាររបស់កូនប្រុសលោក **ខ** ចំនួន ១០០$។ តើករណីនេះចាត់ចូលជាការគ្រប់គ្រងដោយឈឺឆ្អាលដែរឬទេ?

### ២.អត្ថន័យតាមសេចក្ដីផ្ដើមនីតិរដ្ឋប្បវេណីជប៉ុន

ការគ្រប់គ្រងដោយឈឺឆ្អាល គឺសំដៅលើការអនុវត្តកិច្ចការដើម្បីអ្នកដទៃ បើទោះបីជាខ្លួនគ្មានករណីយកិច្ចតាមច្បាប់ដូចជា ករណីយកិច្ចដោយសារកិច្ចសន្យា ឬក៏ករណីយកិច្ចដោយយោងតាមបញ្ញត្តិច្បាប់ក៏ដោយ។[6] ឧទាហរណ៍៖ ដូចជាក្នុងអំឡុងពេលដែលអ្នកជិតខាងធ្វើដំណើរកម្សាន្តទាំងគ្រួសារទៅបរទេស មានខ្យល់ព្យុះដ៏ខ្លាំងធ្វើឲ្យដំបូលផ្ទះមួយផ្នែករបស់អ្នកជិតខាងនោះ បើទោះបីជាអ្នកជិតខាងមិនបានពឹងក៏ដោយ។ ក្នុងករណីបែបនេះ បុគ្គលដែលបានអនុវត្តកិច្ចការដើម្បីអ្នកដទៃហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល រីឯបុគ្គលដទៃដែលទទួលផលប្រយោជន៍ (ក្នុងករណីឧទាហរណ៍ខាងលើនេះ គឺអ្នកជិតខាង) ហៅថាសាមីខ្លួន។

ក្នុងឧទាហរណ៍ដែលបានលើកឡើង ប្រសិនបើខ្លួនបានទទួលនូវការស្នើសុំពីអ្នកជិតខាងឲ្យជួយគ្រប់គ្រងផ្ទះក្នុងអំឡុងពេលអវត្តមានរបស់អ្នកជិតខាង កិច្ចសន្យាអាណត្តិ រវាងភាគីបានកើតឡើង (ដោយសារការគ្រប់គ្រងផ្ទះពុំមែនជាសកម្មភាពគតិយុត្ត បើនិយាយឲ្យជាក់លាក់ នេះគឺជាអាណត្តិមិនពេញលេញ។ ដូច្នេះ ការជួលឲ្យជាងមកធ្វើការជួសជុលដំបូលផ្ទះនេះ គឺអនុលោមទៅតាមកាតព្វកិច្ចដោយផ្អែកលើកិច្ចសន្យា។ ក៏ប៉ុន្តែ ក្នុងករណីដែលមិនត្រូវបានស្នើសុំដោយអ្នកជិតខាងទេ

[6] សេចក្ដីផ្ដើមនីតិរដ្ឋប្បវេណីជប៉ុនរបស់ លោកណូមឹរ៉ា តូយ៉ូហ៊ីរ៉ូ ទំព័រ ១០៨

គឺគ្មានករណីយកិច្ចទៅជួលជាងមកជួសជុលដំបូលផ្ទះនោះទេ។ តែសកម្មភាពជួលជាងមកជួសជុលដំបូលផ្ទះឲ្យអ្នកជិតខាង បើទោះបីជាមិនមានការពឹងពាក់ពីអ្នកជិតខាងក៏ដោយ បែបនេះហើយ គឺជាការគ្រប់គ្រងដោយឈឺឆ្អាល។

ម៉្យាងវិញទៀត ការជួយមនុស្សដែលកំពុងលង់ទឹក ក៏ជាឧទាហរណ៍មួយនៃការគ្រប់គ្រងដោយឈឺឆ្អាលដែរ។ ក៏ប៉ុន្តែ ក្នុងករណីដែលមានករណីយកិច្ចត្រូវជួយសង្គ្រោះតាមច្បាប់(ឧទាហរណ៍ដូចជានគរបាល ឬភ្នាក់ងារពន្លត់អគ្គីភ័យ)។ ការជួយសង្គ្រោះបែបនេះ គឺជាការអនុលោមតាមករណីយកិច្ចរបស់ខ្លួន ពុំមែនជាការគ្រប់គ្រងដោយឈឺឆ្អាលទេ។

## ផ្នែកទី២ ៖ លក្ខខណ្ឌបង្កើត និងប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល

### កថាភាគទី១ ៖ លក្ខខណ្ឌបង្កើតនៃការគ្រប់គ្រងដោយឈឺឆ្អាល

#### ១.លក្ខខណ្ឌទូទៅនៃធ្វើការគ្រប់គ្រងដោយឈឺឆ្អាល

##### ១.១.សមត្ថភាពខាងឆន្ទៈ

សមត្ថភាពខាងឆន្ទៈ សំដៅដល់ការធ្វើសកម្មភាពរបស់បុគ្គលដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន និងមិនអាចលុបចោលបាន (មាត្រា១៤ នៃក្រមរដ្ឋប្បវេណី)។ រីឯពាក្យថា សកម្មភាព គឺមានក្នុង (មាត្រា១៥ មាត្រា៣១១ និងមាត្រា៣១២ នៃក្រមរដ្ឋប្បវេណី)។[7]

##### ១.២.សមត្ថភាពក្នុងការធ្វើសកម្មភាព

សមត្ថភាពក្នុងការធ្វើសកម្មភាព គឺជារបបការពាកុំឲ្យមានការទទួលរងនូវការខូចខាតដែលកើតមានឡើងដោយសារកិច្ចការជួញដូររបស់ជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ និងមិនអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងបាន។ ពោលសំដៅលើជនទាំង បី ប្រភេទ គឺអនីតិជន ជនដែលនៅក្រោមអាណាព្យាបាលទូទៅ និងជនដែលនៅក្រោមហិតូបត្ថម្ភ។[8]

##### ១.៣.សមត្ថភាពអ្នកតំណាងដោយស្វ័យភាពខាងឆន្ទៈ

គោលការណ៍ស្វ័យភាពខាងឆន្ទៈ គឺបង្កើតនូវទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់ជាមួយគ្នាទៅតាមឆន្ទៈរបស់ខ្លួនម្នាក់ៗបានដោយសេរី។ ត្រង់ចំណុចនេះ ក្រមរដ្ឋប្បវេណីបានបង្កើតរបបមួយឲ្យជនម្នាក់ទៀត បង្ហាញឆន្ទៈរបស់ម្ចាស់សិទ្ធិបាន ដោយចាត់ទុកការបង្ហាញឆន្ទៈជំនួសនេះថា ជាការបង្ហាញឆន្ទៈរបស់ម្ចាស់សិទ្ធិផ្ទាល់ ហើយមានអានុភាពផ្លូវច្បាប់ទៅតាមនោះ។ នេះគឺជាការតំណាង

[7] មាត្រា ១៤ ,១៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[8] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដូច្នេះ យើងអាចនិយាយបានថា ការតំណាង គឺជារបបមួយសម្រាប់បំពេញបន្ថែមនូវស្វ័យភាពខាងឆន្ទៈរបស់បុគ្គល។[9]

**២.លក្ខខណ្ឌពិសេសនៃការបង្កើតការគ្រប់គ្រងដោយឈឺឆ្អាល**

ដើម្បីចាត់ទុកថាជាសកម្មភាព ឬ អំពើណាមួយដែលស្ថិតជាការគ្រប់គ្រងដោយឈឺឆ្អាល លុះត្រាតែការគ្រប់គ្រងនោះ ចាំបាច់ត្រូវធ្វើឡើងដោយគ្មានសិទ្ធិអំណាច ដើម្បីការពារផលប្រយោជន៍បុគ្គលដទៃ ហើយអ្នកគ្រប់គ្រងបានចាប់ផ្ដើមគ្រប់គ្រងកិច្ចការ និងការប្រើវិធីសមរម្យបំផុត ឬផ្អែកតាមឆន្ទៈរបស់បុគ្គលដែលជាសាមីខ្លួន (មាត្រា៧២៩ នៃក្រមរដ្ឋប្បវេណី)។

**២.១.ការគ្រប់គ្រងធ្វើឡើងដោយគ្មានសិទ្ធិអំណាច**

ភាពគ្មានសិទ្ធិអំណាច សំដៅលើស្ថានភាពដែលបុគ្គលជាអ្នកគ្រប់គ្រងដោយឈឺឆ្អាល មិនមានសិទ្ធិ ឬមិនទទួលបាននូវសិទ្ធិអំណាចក្នុងការគ្រប់គ្រងលើមនុស្ស ឬទ្រព្យសម្បត្តិនោះឡើយ។ ការគ្រប់គ្រងគ្មានសិទ្ធិអំណាច ត្រូវបានកត់សម្គាល់លើលក្ខខណ្ឌពីរយ៉ាង គឺភាពគ្មានសិទ្ធិអំណាចតាមច្បាប់ និងភាពគ្មានសិទ្ធិអំណាចតាមកិច្ចសន្យា។[10]

**២.១.១.ភាពគ្មានសិទ្ធិអំណាចតាមច្បាប់**

ភាពគ្មានសិទ្ធិអំណាចតាមច្បាប់ សំដៅលើស្ថានភាពមួយដែលច្បាប់បានបញ្ញត្តិទុកថា មិនអនុញ្ញាតឲ្យធ្វើការគ្រប់គ្រងឡើយ ពោលគឺមានលក្ខណៈផ្ទុយពីភាពដែលមានសិទ្ធិអំណាចគ្រប់គ្រង។ ភាពគ្មានសិទ្ធិអំណាចគ្រប់គ្រងអាចត្រូវបានធ្វើការសិក្សាដូចខាងក្រោម៖

**២.១.១.១.ចំពោះបុគ្គល**

ក្នុងករណីលែងលះរវាងប្ដី និងប្រពន្ធដែលតុលាការបានសម្រេចផ្ដល់សិទ្ធិអំណាចមេបាដល់ប្រពន្ធដែលជាម្ដាយនៃកូន ហើយម្ដាយមិនអាចអះអាងថា ខ្លួនបានចិញ្ចឹមបីបាច់ថែរក្សាកូនដើម្បីឪពុក ហើយខ្លួនសុំទាមទារឪពុកបំពេញកាតព្វកិច្ច ឬបង់ប្រាក់ផ្សេងៗទៀត ត្រង់ចំណុចនេះបញ្ជាក់ថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវតែមិនមែនជាអ្នកមានអំណាចមេបាលើអ្នកដែលខ្លួនគ្រប់គ្រងទេ។ ផ្ទុយទៅវិញ ឪពុកដែលមិនមានអំណាចមេបា ពេលដែលខ្លួនបានគ្រប់គ្រងកូនរបស់ខ្លួន ក៏មិនអាចទាមទារសោហ៊ុយ ឬកម្រៃដោយផ្អែកលើការគ្រប់គ្រងដោយឈឺឆ្អាលបានដែរ។

អ្នកអាណាព្យាបាលទូទៅ គឺជាអ្នកតំណាងតាមច្បាប់កំណត់របស់ជនដែលនៅស្ថិតក្រោមអាណាព្យាបាលទូទៅ ហើយក៏មិនអាចអះអាងថា ខ្លួនធ្វើការគ្រប់គ្រង និងថែរក្សាជននៅស្ថិតក្រោមអាណាព្យាបាលទូទៅ គឺជាការគ្រប់គ្រងដោយឈឺឆ្អាលបានដែរ ដោយហេតុថាទំនាក់ទំនងនៃរបប

[9] មាត្រា ៣៧៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[10] មាត្រា ៧២៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អាណាព្យាបាលទូទៅនេះ គឺត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់តុលាការ ដែលមិនមែនជាស្ថានភាពដែលអ្នកអាណាព្យាបាលគ្មានសិទ្ធិអំណាចគ្រប់គ្រងនោះទេ ។[11]

ហិតូបត្ថម្ភកៈ ដែលជាអ្នកតំណាងឲ្យជននៅក្រោមហិតូបត្ថម្ភ ក៏មិនអាចទាមទារសោហ៊ុយនៃការគ្រប់គ្រងដោយផ្អែកលើការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ ដោយហេតុថាទំនាក់ទំនងនៃរបបហិតូបត្ថម្ភនេះ ក៏ត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់តុលាការដែរ។[12]

**២.១.១.២.ចំពោះទ្រព្យ**

ភាពគ្មានសិទ្ធិអំណាចក្នុងគ្រប់គ្រងលើទ្រព្យចាំបាច់ត្រូវតែ៖

①. អ្នកគ្រប់គ្រងដោយឈឺឆ្អាល មិនមែនជាកម្មសិទ្ធិករនៃទ្រព្យសម្បត្តិ ដែលជាកម្មវត្ថុនៃការគ្រប់គ្រងនោះទេ ដូច្នេះការគ្រប់គ្រងដោយឈឺឆ្អាលលើទ្រព្យនោះ សំដៅលើការគ្រប់គ្រងលើទ្រព្យរបស់អ្នកដទៃតែប៉ុណ្ណោះ។

②. ក្រៅពីនេះទៅទៀតនោះ ភាពគ្មានសិទ្ធិអំណាចគ្រប់គ្រងរបស់អ្នកគ្រប់គ្រង ក៏សំដៅលើស្ថានភាពដែលអ្នកគ្រប់គ្រងមិនអាចធ្វើការគ្រប់គ្រងបាន ក្នុងឋានៈខ្លួនជាអ្នកអាចគ្រប់គ្រងបាន។

**២.១.២.ភាពគ្មានសិទ្ធិអំណាចតាមកិច្ចសន្យា**

ភាពគ្មានសិទ្ធិអំណាចគ្រប់គ្រងតាមកិច្ចសន្យា សំដៅលើស្ថានភាពមួយដែលមិនមានការគិតទុកមុនរវាងអ្នកគ្រប់គ្រងដោយឈឺឆ្អាល និងសាមីខ្លួន ហើយបានធ្វើការគ្រប់គ្រងលើបុគ្គលនោះ។ ដោយលក្ខខណ្ឌមិនបានព្រមព្រៀងគ្នាតាមឆន្ទៈជាមុនតាមរយៈកិច្ចសន្យានោះទេ ទោះបីជាធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្តី និងភាពគ្មានឆន្ទៈបង្ខិតបង្ខំ ដូចខាងក្រោម៖

**២.១.២.១.ការមិនបានព្រមព្រៀងគ្នាទុកជាមុនតាមកិច្ចសន្យា**

ការមិនបានព្រមព្រៀងគ្នាឆន្ទៈទុកជាមុនតាមរយៈកិច្ចសន្យា សំដៅទៅលើអ្នកដែលត្រូវបានគេគ្រប់គ្រង ឬអ្នកតំណាងរបស់អ្នកដែលត្រូវបានគេគ្រប់គ្រងមិនបានធ្វើការយល់ព្រមឲ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាល មុនពេលចាប់ផ្តើមធ្វើការគ្រប់គ្រងនោះទេ។ ករណីនេះ អ្នកគ្រប់គ្រងដោយឈឺឆ្អាលក៏មិនមែនជាអ្នកដែលទទួលបាននូវការគ្រប់គ្រងលើទ្រព្យរបស់អ្នកដទៃនោះទេ តាមរយៈកិច្ចសន្យានោះដែរ ទោះជាកិច្ចសន្យានោះធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ក៏ដោយ។

ឧទាហរណ៍៖ ភតិកៈ បានធ្វើការគ្រប់គ្រងថែរក្សាផ្ទះដែលជាកម្មវត្ថុនៃភតិសន្យា ហើយបែរជាទាមទារឲ្យភតិបតី បង់សោហ៊ុយចំណាយនៃការជួសជុលផ្សេងៗ ដោយផ្អែកលើការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ។

[11] មាត្រា២៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[12] មាត្រា២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ប៉ុន្តែករណីខ្លះ លោក **ក** បានឃើញផ្ទះលោក **ខ** ខូចបង្អួចពេលដែលលោក **ខ** មិននៅផ្ទះ រយៈពេលយូរថ្ងៃកន្លងមក ហើយលោក **ក** បានទូរស័ព្ទទៅលោក **ខ** ដើម្បីប្រាប់អំពីហេតុការណ៍នេះ លោក **ខ** ក៏បានស្នើសុំឲ្យលោក **ខ** ជួយជួសជុលឲ្យផង។ ករណីនេះ ក៏ចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលដែរ។

#### ២.១.២.២.ភាពគ្មានលក្ខណៈបង្ខិតបង្ខំ

ភាពគ្មានឆន្ទៈបង្ខិតបង្ខំ គឺជាស្ថានភាពមួយដែលអ្នកគ្រប់គ្រងសម្តែងឆន្ទៈផ្ទាល់ ហើយមានការសម្រេចចិត្តដោយខ្លួនឯង និងគ្មានការបង្គាប់បញ្ជាពីអ្នកដទៃ មានន័យថា អ្នកគ្រប់គ្រងធ្វើឡើងក្នុងគោលបំណងដើម្បីការពារនូវទ្រព្យសម្បត្តិ និងកុំឲ្យមានការបាត់បង់បន្ថែមទៀត និងកើតចេញពីឆន្ទៈសុច្ចរិត ស្មោះត្រង់ ចេះជួយគ្នាទៅវិញទៅមកក្នុងនាមជាបុគ្គលល្អរបស់សង្គម។ គួរធ្វើការពិចារណាដែលថា ប្រសិនបើអ្នកគ្រប់គ្រងបានធ្វើការគ្រប់គ្រងលើទ្រព្យដែលខ្លួនមានសិទ្ធិគ្រប់គ្រង តែក៏ដើម្បីផលប្រយោជន៍ផ្ទាល់ផង និងផលប្រយោជន៍បុគ្គលដទៃផងដែរ។

ឧទាហរណ៍៖ ប្រសិនបើមានច្រាំងទន្លេត្រូវបានបាក់ ដោយសារការកើនឡើងនៃទឹកទន្លេ ហើយមានអ្នករស់នៅក្បែរដងទន្លេម្នាក់ឈ្មោះ **ក** បានចាត់វិធានការជាបន្ទាន់ដើម្បីទប់ស្កាត់ការបាក់ច្រាំងទន្លេ ដើម្បីការពារផ្ទះអ្នកជិតខាង និងផ្ទះរបស់ខ្លួនផងដែរ។ សកម្មភាពបែបនេះនឹងត្រូវចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាល (សេចក្តីកំណត់មាត្រានីមួយៗ នៃក្រមរដ្ឋប្បវេណី ភាគទី៣ គន្ថីទី៥ ត្រង់ចំណុចមាត្រា៧២៩)។ តាមរយៈឧទាហរណ៍នេះ វាហាក់ដូចជាមានលក្ខណៈផ្ទុយពីលក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាល ត្រង់ភាពគ្មានសិទ្ធិអំណាចគ្រប់គ្រង។ តែនៅក្នុងឧទាហរណ៍នេះ អ្នកគ្រប់គ្រង បានគ្រប់គ្រងលើដីខ្លួនឯង ដើម្បីប្រយោជន៍ខ្លួនឯងផង និងប្រយោជន៍អ្នកដទៃផង មានន័យថា អ្នកគ្រប់គ្រងបានធ្វើការគ្រប់គ្រង ដើម្បីប្រយោជន៍អ្នកដទៃ ដែលជាលក្ខខណ្ឌមួយនៃការគ្រប់គ្រងដោយឈឺឆ្អាល។

### ២.២.ការគ្រប់គ្រងធ្វើឡើងដើម្បីបុគ្គលដទៃ

ពាក្យថា បុគ្គលដទៃ[13] អាចត្រូវបានគេធ្វើការបកស្រាយតាមអត្ថន័យ ពីរយ៉ាងក្រោម៖

អត្ថន័យទី១៖ បុគ្គលដទៃ សំដៅលើបុគ្គលទាំងឡាយណាដែលមិនមែនជាញាតិលោហិតរបស់ខ្លួនឯង។ យោងតាមមាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណី បានកំណត់ពីបុគ្គលដែលត្រូវបានចាត់ទុកថា ញាតិ គឺសំដៅលើញាតិលោហិតក្នុង ៦ថ្នាក់ សហព័ទ្ធ និងញាតិពន្ធក្នុង ៣ថ្នាក់។ តាមខ្លឹមសារការគ្រប់គ្រងកិច្ចការដើម្បីញាតិខ្លួនឯង ទោះបីជាលក្ខខណ្ឌទាំងឡាយនៃការគ្រប់គ្រងដោយឈឺឆ្អាល

[13] មាត្រា ៧២៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ត្រូវបានបំពេញ ក៏មិនមែនជា "ការគ្រប់គ្រងដោយឈឺឆ្អាល" ដែរ។ ដូច្នេះ អ្នកគ្រប់គ្រងមិនអាចទាមទារឲ្យម្ចាស់ទ្រព្យ ឬសាមីខ្លួនដែលជាញាតិរបស់អ្នកគ្រប់គ្រងនោះ ឲ្យបង់នូវសោហ៊ុយចំណាយលើការគ្រប់គ្រង និងកម្រៃនៃការគ្រប់គ្រងដោយផ្អែកលើការគ្រប់គ្រងដោយឈឺឆ្អាលបានទេ។ ករណីនេះវាហាក់ដូចជាមិនសូវមានភាពយុត្តិធម៌ដល់អ្នកគ្រប់គ្រងសោះ ដោយហេតុថា ដោយគ្រាន់តែសំអាងថាមានទំនាក់ទំនងញាតិមិនចាំបាច់ត្រូវបង់សោហ៊ុយ និងកម្រៃ ដោយសារការគ្រប់គ្រងដែរ ឬទេ? បើដូច្នេះមែន ទោះបីមានទំនាក់ទំនងញាតិរវាងគ្នាក្តី ក៏រវាងញាតិម្នាក់ៗ និងមិនជួយគ្នាទៅវិញទៅមកតទៅទៀត ព្រោះការជួយបានត្រឹមតែចំណាយទ្រព្យសម្បត្តិផ្ទាល់ខ្លួនតែប៉ុណ្ណោះ។

អត្ថន័យទី២៖ បុគ្គលដទៃ សំដៅលើបុគ្គលទាំងឡាយណាដែលក្រៅពីខ្លួនឯង។ ករណីនេះក៏នឹងមានសំណួរលើកឡើងថា ចុះការគ្រប់គ្រងកិច្ចការដើម្បីប្រពន្ធខ្លួនឯង ឬឪពុកម្តាយខ្លួនឯង ឬកូនខ្លួនឯង ត្រូវចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាលដែរទេ ប្រសិនបើលក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាលទាំងឡាយត្រូវបានបំពេញ?

ឧទាហរណ៍៖ បុរស A មានផ្ទះមួយកន្លែងនៅខេត្តកណ្តាលនៅមុនពេលដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយ B។ ផ្ទះនេះ គឺជាទ្រព្យសម្បត្តិដោយឡែករបស់ A។ ថ្ងៃមួយនារី B ដែលជាប្រពន្ធរបស់ឈ្មោះ A បានទៅធ្វើការនៅត្បូងឃ្មុំ។ នៅពេលធ្វើដំណើរនោះ ឈ្មោះ B ក៏បានឃើញផ្ទះរបស់ឈ្មោះ A ធ្លុះដំបូល ពេលនោះខ្លួនក៏ជួលជាងដើម្បីមកជួសជុលឲ្យ B។ តើករណីនេះចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាលដែរ ឬទេ?

តាមរយៈការប្រៀបធៀបគ្នារវាងអត្ថន័យនៃបុគ្គលដទៃទាំងពីរខាងលើនេះ គេនឹងសង្កេតឃើញថា អត្ថន័យទី២ មានភាពសមរម្យ និងអាចយកមកអនុវត្តបាននៅក្នុងបរិបទនៃការគ្រប់គ្រងដោយឈឺឆ្អាលនៅក្រមរដ្ឋប្បវេណីបាន ទោះបីជាមានបញ្ហាដូចបានលើកឡើងខាងលើក៏ដោយ។ នៅក្នុងទំនាក់ទំនងប្តីប្រពន្ធ៖ ប្តីប្រពន្ធមានករណីយកិច្ចរួមរស់ជាមួយគ្នាទាំង ជីវភាព សហការ និងសង្គ្រោះគ្នាទៅវិញទៅមក (មាត្រា៩៦៦ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះតាមខ្លឹមសារនេះ ជាករណីពិសេសដែលប្តីប្រពន្ធអាចធ្វើការគ្រប់គ្រងកិច្ចការដើម្បីសហព័ទ្ធរបស់ខ្លួនរៀងៗខ្លួនបាន ដោយមិនចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាលបានឡើយ។

### ២.៣.ការគ្រប់គ្រងដើម្បីផលប្រយោជន៍

ការគ្រប់គ្រងដើម្បីជាប្រយោជន៍ក្នុងន័យនេះ គឺមិនសំដៅតែសាមីខ្លួនប៉ុណ្ណោះទេ។ គេអាចចាត់ទុកថាមានការគ្រប់គ្រងដោយឈឺឆ្អាល កាលណាអ្នកគ្រប់គ្រងធ្វើកិច្ចការដើម្បីខ្លួនឯង និងដើម្បី

សាមីខ្លួន។[14] ទស្សនៈនេះក្នុងទ្រឹស្តីច្បាប់រដ្ឋប្បវេណីប្រទេសចិនក៏បានទទួលស្គាល់ផងដែរ ដោយសារមានធាតុការធ្វើកិច្ចការដើម្បីប្រយោជន៍អ្នកដទៃ។ បន្ថែមពីទ្រឹស្តីនេះផងដែរ ការធ្វើកិច្ចការដើម្បីផលប្រយោជន៍អ្នកដទៃដោយការភាន់ច្រឡំ ក៏ត្រូវបានបញ្ញត្តិថាជាការគ្រប់គ្រងដោយឈឺឆ្អាលផងដែរ។ បើងាកមកពិនិត្យចំពោះក្រមរដ្ឋប្បវេណីកម្ពុជាវិញ យើងអាចកត់សម្គាល់ឃើញការចូលទៅគ្រប់គ្រងទ្រព្យរបស់អ្នកដទៃហាក់ដូចជាបញ្ជាក់ ការគ្រប់គ្រងអាចធ្វើបានលុះត្រាស្គាល់ពីអត្តសញ្ញាណម្ចាស់ទ្រព្យ ហើយព្រមជាមួយគ្នានោះ មិនបានចែងពីករណីដែលអ្នកគ្រប់គ្រងចូលទៅគ្រប់គ្រងដោយច្រឡំបុគ្គលនោះទេ។

ឧទាហរណ៍៖ លោក A បានចូលទៅគ្រប់គ្រងផ្ទះលោក B ដោយសារស្មានថាផ្ទះនោះជារបស់លោក C ហើយ A បានគ្រប់គ្រងដោយចេញសោហ៊ុយក្នុងការគ្រប់គ្រង។ ករណីច្បាប់រដ្ឋប្បវេណីប្រទេសថៃទទួលស្គាល់ថា នេះជាការគ្រប់គ្រងដោយឈឺឆ្អាល។ ចំពោះក្រមរដ្ឋប្បវេណីកម្ពុជា ទោះបីមិនបានចែងក៏ដោយ ក៏នេះជាការគ្រប់គ្រងដោយឈឺឆ្អាលផងដែរ ដោយសារធាតុផ្សំគ្រប់គ្រងកិច្ចការដើម្បីប្រយោជន៍អ្នកដទៃ ឬអាចជាករណីនៃសេចក្តីចម្រើនដោយឥតហេតុ។

### ២.៤.អ្នកគ្រប់គ្រងចាប់ផ្តើមគ្រប់គ្រងកិច្ចការ

ការចាប់ផ្តើមបំពេញកិច្ចការ សំដៅការចាប់ផ្តើមបំពេញកិច្ចការគតិយុត្ត ដែលអាចបង្កើតកិច្ចសន្យាជាមួយនឹងតតិយជន ឬធ្វើសកម្មភាពបំពេញកិច្ចការគតិយុត្ត ជាដើម។[15]

ឧទាហរណ៍៖ លោក **ក** មានផ្ទះមួយខ្នងនៅជាប់ផ្ទះ លោក **ខ**។ លោក **ក** បានធ្វើចំណាកស្រុកទៅធ្វើការនៅប្រទេសថៃ។ នៅថ្ងៃមួយមានភ្លៀង និងខ្យល់បោកបក់យ៉ាងខ្លាំងបណ្តាលឲ្យផ្ទះលោក **ក** បានរបើកស័ង្កសីអស់ចំនួន ៨ផ្ទាំង។ លោក **ខ** ឃើញដូចនេះក៏បានទៅទិញស័ង្កសីយកមកប្រក់ផ្ទះជូនលោក **ក** វិញ ព្រោះខ្លួនគិតថា ប្រសិនបើមិនធ្វើដូច្នេះទេ ទ្រព្យសម្បត្តិដែលនៅក្នុងផ្ទះរបស់លោក **ក** នឹងខូចខាត ឬបាត់បង់ជាមិនខាន។

សកម្មភាពដែលលោក **ក** បានទៅទិញស័ង្កសី គឺមានន័យថា លោក **ក** បានចុះកិច្ចសន្យាទិញលក់ស័ង្កសីជាមួយនឹងអ្នកលក់។ រីឯលោក **ក** បានធ្វើចាប់ផ្តើមយកមកប្រក់ស័ង្កសីនេះ គឺជាសកម្មភាពឯកតោភាគី ដែលលោក **ក** បានធ្វើឡើងដើម្បីលោក **ខ**។ ករណីនេះ លោក **ក** ក៏អាចជួលជាង ដើម្បីមកប្រក់ស័ង្កសីជូនលោក **ខ** បានដែរ (គឺជាកិច្ចសន្យារវាងលោក **ក** និងជាង)។

[14] មាត្រា ៧២៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[15] មាត្រា ៧២៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ២.៥.ការគ្រប់គ្រងធ្វើឡើងដោយវិធីសមរម្យ ឬតាមឆន្ទៈបុគ្គលសាមីខ្លួន

ក្នុងករណីដែលអ្នកគ្រប់គ្រងដោយឈឺឆ្អាលបានដឹង ឬអាចដឹងអំពីឆន្ទៈរបស់សាមីខ្លួន (ភាគីម្ខាងទៀត) នោះ អ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវធ្វើការគ្រប់គ្រង ដោយផ្អែកតាមឆន្ទៈរបស់បុគ្គលដែលជាសាមីខ្លួននោះ។ ករណីដែលមិនបានដឹងទេ អ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវធ្វើការគ្រប់គ្រងដោយព្យាយាមដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុច្ចរិត តាមវិធីដែលសមរម្យជាងគេដើម្បីប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការ។[16]

ក្នុងក្រមរដ្ឋប្បវេណី បានចែងពីបញ្ញប់ការការគ្រប់គ្រងប្រសិនបើ អ្នកគ្រប់គ្រងបានដឹងថាការគ្រប់គ្រងនោះនឹងធ្វើឲ្យខូចប្រយោជន៍ ឬ ផ្ទុយពីឆន្ទៈរបស់ខ្លួន។ ក៏ប៉ុន្តែផ្អែកតាមក្រមរដ្ឋប្បវេណីប្រទេសថៃ គឺអនុញ្ញាតឲ្យធ្វើការបន្តគ្រប់គ្រងកាលណាការគ្រប់គ្រងនោះ ដើម្បីប្រយោជន៍សាធារណៈ ហើយដែលមិនអាចរំពឹងថា សាមីខ្លួននឹងមកធ្វើកិច្ចការនោះបានទាន់ពេលវេលាដែរ។ ត្រង់ចំណុចនេះក្រមរដ្ឋប្បវេណីបានផ្ដល់អាទិភាពដល់ផលប្រយោជន៍សាធារណៈធំជាងផលប្រយោជន៍ឯកជន បើទោះបីជាអ្នកគ្រប់គ្រងបានដឹងថា ផ្ទុយពីឆន្ទៈរបស់សាមីខ្លួនក៏ដោយ។

ឧទាហរណ៍៖ ក្នុងករណីដែលលោក **ក** ជាម្ចាស់ផ្ទះបានប្រាប់ឲ្យលោក **ខ** ដែលជាអ្នកគ្រប់គ្រងដោយឈឺឆ្អាល លើហេតុការណ៍ជួសជុលទ្វាផ្ទះរបស់ខ្លួន ថាឲ្យទិញទ្វាថ្មីមកដាក់ជំនួសទ្វារចាស់ដោយសារទ្វារចាស់នោះជួសជុលលែងកើតហើយ។ ហើយលោក **ខ** បានអនុវត្តតាមឆន្ទៈរបស់សាមីខ្លួន។ ផ្ទុយទៅវិញបើលោក **ខ** បានទិញទ្វារនោះខុសពីឆន្ទៈរបស់សាមីខ្លួន ហើយមានគំនិតចង់កេងចំណេញបានទិញទ្វារចាស់វិញ ការគ្រប់គ្រងនេះ គឺជាការគ្រប់គ្រងធ្វើឡើងមិនតាមវិធីសមរម្យដែលអាចទទួលយកបានទេ។

ករណីខ្លះ ការគ្រប់គ្រងលើបុគ្គលវិញ ដូចជាស្ថានភាពដែលឃើញបុគ្គលម្នាក់ជួបគ្រោះថ្នាក់ចរាចរណ៍នៅលើផ្លូវ ប្រសិនបើមិនមានអ្នកណាជួយសង្គ្រោះគាត់ទេ បុគ្គលម្នាក់នោះនឹងបាត់បង់ជីវិតហេតុដូច្នេះហើយ ទើបអ្នកគ្រប់គ្រងដោយឈឺឆ្អាលធ្វើការជួយសង្គ្រោះ បុគ្គលម្នាក់នោះ យកទៅមន្ទីរពេទ្យដើម្បីព្យាបាលសង្គ្រោះ និងបានចំណាយលុយថ្លៃព្យាបាលជំនួសជនរងគ្រោះ។ ប៉ុន្តែការជួយសង្គ្រោះបែបនេះត្រូវមើលលើស្ថានភាពកាលៈទេសៈ និងធនធាននៃជនរងគ្រោះ ហើយធ្វើយ៉ាងណាឲ្យបានសមរម្យ ដើម្បីឲ្យជនរងគ្រោះមានលទ្ធភាពក្នុងការសងរាល់ការចំណាយមកអ្នកគ្រប់គ្រងដោយឈឺឆ្អាលវិញ។

[16] មាត្រា ៧២៩ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## កថាភាគទី២.៖ ប្រភេទនៃការគ្រប់គ្រងដោយឈឺឆ្អាល

### ១.ការគ្រប់គ្រងត្រូវធ្វើឡើងចំពោះបុគ្គល និងទ្រព្យ

#### ១.១.ចំពោះបុគ្គល

ការគ្រប់គ្រងដោយឈឺឆ្អាលចំពោះបុគ្គល គឺការផ្តោតសំខាន់ទៅលើរូបវន្តបុគ្គលដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព និងផលប្រយោជន៍ទាក់ទងនឹងបុគ្គលនេះ។ ក្នុងករណីបុគ្គលនេះ មិនអាចជួយខ្លួនឯងបាននៅពេលជួបគ្រោះថ្នាក់ ឬស្ថានភាពអាសន្ន ឬ ឧបទ្ទវហេតុណាមួយដោយចៃដន្យ ហើយត្រូវអ្នកដទៃជួយសង្គ្រោះក្នុងន័យចេះជួយយកអាសារ មើលថែរក្សាគ្នាដោយប្រព្រឹត្តទៅតាមគន្លងសីលធម៌របស់សង្គម។[17]

ឧទាហរណ៍៖ លោក **ក** មានកូនពីរនាក់ ម្នាក់មានអាយុ៥ឆ្នាំ និងម្នាក់ទៀតអាយុ៧ឆ្នាំ នៅពេលចេញទៅធ្វើការគាត់ភ្លេចទុកលុយឲ្យកូនទិញចំណីអាហារញ៉ាំរយៈពេលមួយថ្ងៃ។ លោក **ខ** ជាអ្នកជិតខាងបានឃើញកូនរបស់លោក **ក** ទាំងពីរកំពុងជួបប្រទះនឹងបញ្ហាអត់ឃ្លាន ក្នុងស្ថានភាពលោក **ក** មិននៅ លោក **ខ** បានចំណាយលុយទិញចំណីអាហារឲ្យកូនលោក ក ញ៉ាំដើម្បីចៀសវាងការអត់អាហារស្លាប់។

#### ១.២.ចំពោះទ្រព្យសម្បត្តិ

ការគ្រប់គ្រងលើទ្រព្យសម្បត្តិ សំដៅលើបុគ្គលដែលអវត្តមានពីលំនៅដ្ឋាន ឬទីសំណាក់ ឬទីកន្លែងនៃទ្រព្យ ហើយមិនអាចមានលទ្ធផលវិលត្រឡប់មកគ្រប់គ្រងវិញបាន។ ក្នុងកាលៈទេសៈនេះ បុគ្គលដទៃមកធ្វើការគ្រប់គ្រងដើម្បីការពារនូវអត្ថប្រយោជន៍នៃទ្រព្យសម្បត្តិនេះ កុំឲ្យមានការបាត់បង់ ឬ ខូចខាត ដែលគេភាគច្រើននិយាយថាមើលនឹងភ្នែក។ មានន័យថា បង្កើតនៅទំនាក់ទំនងមួយឲ្យមនុស្សចេះជួយគ្នានៅគ្រានាពេលមានអាសន្ន ដែលការគ្រប់គ្រងត្រូវធ្វើឡើងដោយគោរពនូវគោលការណ៍ភាពសុចរិត និង ភាពស្មោះត្រង់ ក្នុងការគ្រប់គ្រងទ្រព្យនោះ។[18]

### ២.ការគ្រប់គ្រងធ្វើឡើងក្នុងស្ថានភាពបន្ទាន់

#### ២.១.ការការពារស្ថានចាំបាច់

ការការពារស្ថានចាំបាច់ សំដៅលើការការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឆាំងនឹងឧបទ្ទវហេតុដែលបានកំពុងកើតមាន ឬដែលនឹងកើតមានឡើង។ ករណីនេះ ការគ្រប់គ្រងក្នុងស្ថានភាពបន្ទាន់ត្រូវធ្វើឡើងដោយសកម្មភាពពីរគឺ សកម្មភាពឯកតោភាគី និង ការជួយសង្គ្រោះ

---

[17] មាត្រា ៧៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[18] មាត្រា ៧៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ដើម្បីជៀសវាងគ្រោះថ្នាក់។ ម៉្យាងទៀត ក្នុងការការពារស្ថានភាពចាំបាច់ វាត្រូវតែស្តែងតាមរយៈសកម្មភាពពីរ គឺសកម្មភាពឯកតោភាគី និងសកម្មភាពឆ្លើយតបនឹងការជួយសង្គ្រោះបន្ទាន់។

### ២.១.១.សកម្មភាពឯកតោភាគី

សកម្មភាពឯកតោភាគី គឺសំដៅលើអ្នកគ្រប់គ្រងដែលធ្វើឡើងដោយម្នាក់ឯង នៅពេលដែលជួបប្រទះព្រឹត្តិការណ៍កើតឡើងហើយ បុគ្គលជាអ្នកគ្រប់គ្រងនេះសម្រេចចិត្តជួយសង្គ្រោះ ដើម្បីបញ្ចៀសនូវឧបទ្ទវហេតុធ្ងន់ធ្ងរ ក៏ដូចជាដើម្បីការពារនូវផលប្រយោជន៍របស់សាមីខ្លួន។ មានន័យថាប្រសិនបើអ្នកគ្រប់គ្រងនោះ មិនជួយក្នុងស្ថានភាពបន្ទាន់នោះទេ ជាលទ្ធផលវានឹងធ្វើឲ្យបាត់បង់ ឬខូចខាតយ៉ាងធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ឬ អាយុជីវិតរបស់សាមីខ្លួន។

ឧទាហរណ៍៖ ហេតុការណ៍មួយបានកើតឡើងភ្លាមៗ ចំពោះផ្ទះលោក **ក** ដោយសារអគ្គិភ័យកំពុងឆាប់ឆេះឡើងយ៉ាងសន្ធោសន្ធៅ។ ហើយលោក **ខ** ជាអ្នកជិតខាងនឹងគ្នាបានឃើញហេតុការណ៍នេះ ក៏ប្រញាប់ប្រញាល់ជូលអ្នកពន្លត់អគ្គីភ័យមកពន្លត់ ដោយបានចំណាយលុយរបស់ខ្លួន ករណីនេះ លោក **ខ** ធ្វើឡើងដោយឯកឯង ដើម្បីជួយសង្គ្រោះផ្ទះលោក **ក** ហើយរួចរាល់ពីហេតុការណ៍ទើបលោក **ខ** បានជូនដំណឹងតាមក្រោយ។

### ២.១.២.សកម្មភាពឆ្លើយតបនឹងការសង្គ្រោះបន្ទាន់

សកម្មភាពឆ្លើយតបនឹងការសង្គ្រោះបន្ទាន់ សំដៅទៅលើដំណាក់កាលមួយក្នុងពេលមានឧបទ្ទវហេតុនោះ ដោយអ្នកគ្រប់គ្រងបានចាត់ចែងសម្របសម្រួលលើរាល់ការគ្រប់គ្រង ដើម្បីឆ្លើយតបនឹងស្ថានភាពប្រឈមដែលកំពុងនឹងកើត ហើយធ្វើការទប់ស្កាត់នូវការរីករាលដាលនៃឧបទ្ទវហេតុនោះ និងធ្វើឲ្យមានស្ថានភាពល្អប្រសើរឡើងវិញ។ ជាទូទៅការឆ្លើយបតអំពីហេតុការណ៍នេះ គឺបញ្ជាក់ឲ្យសាមីខ្លួនពីភាពបន្ទាន់នៃព្រឹត្តិការណ៍ ក្នុងអំឡុងពេលដែលខ្លួនមិនដឹងទាល់តែសោះ និងត្រូវបញ្ជាក់ពីចំណុចសំខាន់ចំពោះសកម្មភាពរបស់ខ្លួន ដើម្បីជៀសវាងការប្រកែកគ្នាពេលក្រោយ។ ការឆ្លើយបតនេះ មានន័យថា សាមីខ្លួន និងអ្នកគ្រប់គ្រងដោយឈឺឆ្អាលមានទំនាក់ទំនងសកម្មភាពជាមួយគ្នារហូតដល់ពេលចប់ហេតុការណ៍នេះ។[19]

## ២.២.ការគ្រប់គ្រងដោយគ្មានគំនិតទុច្ចរិត

ការគ្រប់គ្រងដោយគ្មានគំនិតទុច្ចរិត គឺសំដៅទៅលើឆន្ទៈរបស់អ្នកគ្រប់គ្រងក្នុងការប្រតិបត្តិកិច្ចការដោយគ្មានចេតនាបន្លំ ឬ កេងប្រវ័ញ្ចឬ កេងចំណេញក្នុងទិសដៅដើម្បីរកកម្រៃដែលកើតចេញពីការគ្រប់គ្រងដែលខ្លួនបានធ្វើឡើយ ដែលជាហេតុនាំឲ្យខូចខាតផលប្រយោជន៍របស់សាមីខ្លួន។

[19] មាត្រា ៧៣០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ត្រង់ចំណុចនេះ មានន័យថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវតែជាបុគ្គលសុចរិត ស្មោះត្រង់ និងមានសីលធម៌ចេះជួយគ្នាដែលអះអាងតាមរយៈសកម្មភាពធ្វើការគ្រប់គ្រងជាក់ស្តែង។

ឧទាហរណ៍៖ លោក ខ ជាជួយសង្គ្រោះលោក ក ពីហេតុការណ៍ផ្ទុះហ្គាសឡាន។ ហើយលោក ខ បានជូនលោក ក ទៅមន្ទីរពេទ្យនឹងបានចេញការចំណាយថ្លៃព្យាបាលផ្សេងៗទៀត ប៉ុន្តែករណីនេះ គឺលោក ខ មិនត្រូវឲ្យខាងមន្ទីរពេទ្យធ្វើវិកយប័ត្របន្ថែមតម្លៃពីលើថ្លៃព្យាបាលពិតប្រាកដទេ ប្រសិនបើជាគាត់មានគំនិតទុច្ចរិតមិនត្រូវចាត់ទុកថា ការគ្រប់គ្រងដោយឈឺឆ្អាលបានទេ។

ជាគោលការណ៍ ការគ្រប់គ្រងដោយគ្មានគំនិតទុច្ចរិត ត្រូវបានគេសង្កេតឃើញមានទៅលើស្ថានភាព ពីរ យ៉ាងគឺ៖

### ២.២.១.ការគ្រប់គ្រងដោយគ្មានកំហុស

ការគ្រប់គ្រងដោយគ្មានកំហុស សំដៅលើករណីអ្នកគ្រប់គ្រងបានដឹងអំពីគោលបំណង ឬការណែនាំរបស់សាមីខ្លួន ហើយអ្នកគ្រប់គ្រងអនុវត្ត ឬធ្វើតាមគោលបំណង ឬការណែនាំនោះ។ ប៉ុន្តែប្រសិនបើអ្នកគ្រប់គ្រងពុំបានដឹងអំពីគោលបំណង ឬការណែនាំរបស់សាមីខ្លួនទេ អ្នកគ្រប់គ្រងត្រូវធ្វើការគ្រប់គ្រងដោយផ្អែកលើកាលៈទេសៈ ដែលសមស្របអាស្រ័យតាមស្ថានភាពជាក់ស្តែង។

ឧទាហរណ៍៖ ផ្ទះមួយនឹងទុយោទឹកបែក ហើយផ្ទះនឹងជាប់សោរ បើសិនជាយើងកាត់សោរយើងមានកំហុស ដូច្នេះយើងត្រូវផ្តល់ដំណឹងនេះទៅដល់ម្ចាស់ផ្ទះ។

### ២.២.២.ការមិនទទួលខុសត្រូវលើសំណងនៃការខូចខាត

ការគ្រប់គ្រងដោយឈឺឆ្អាលស្ថិតនៅក្នុងស្ថានភាពបន្ទាន់ទៅលើបុគ្គល ដូចជាទ្រព្យ ឬបុគ្គល បុគ្គលដែលជាអ្នកគ្រប់គ្រងពុំមានការទទួលខុសត្រូវលើសំណងនៃការខូចខាតកើតឡើង ដោយសារការគ្រប់គ្រងឡើយ។ ប៉ុន្តែចំណុចនេះក៏ត្រូវបញ្ជាក់ថា វាមិនមែនជាកំហុសរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាលទេ។

ជាធម្មតាការចូលទៅគ្រប់គ្រងក្នុងស្ថានភាពណាមួយ គឺជាការសម្តែងតាមឆន្ទៈចង់ជួយគ្នាក្នុងនាមជាមនុស្សមានសមធម៌ សីលធម៌ និងស្គាល់ពីហេតុផលបានត្រឹមត្រូវចំពោះកាលៈទេសៈនីមួយៗ ដែលកើតឡើងដោយចៃដន្យ។

ឧទាហរណ៍៖ ក្នុងករណីមួយមានភ្លើងឆេះផ្ទះ ហើយអ្នកគ្រប់គ្រងគាត់បានធ្វើការគ្រប់គ្រងដោយប្រុងប្រយ័ត្នចំពោះកិច្ចការនេះ។ ក្រោយពីស្ថានភាពនេះបានបញ្ចប់រួចរាល់ហើយ ក៏អ្នកគ្រប់គ្រងដោយឈឺឆ្អាលប្រគល់ការគ្រប់គ្រងនេះ ឲ្យទៅសាមីខ្លួនវិញ។ ក្រោយពីបានទទួលវិញសាមីខ្លួនបានប្រាប់អ្នកគ្រប់គ្រងថា មានការបាត់បង់ទ្រព្យសម្បត្តិមួយចំនួនដោយសារការគ្រប់គ្រងនេះ ប៉ុន្តែសាមីខ្លួនមិនអាចបញ្ជាក់ថា ជាកំហុសរបស់អ្នកគ្រប់គ្រងទេ។

# ជំពូកទី២

#ករណីយកិច្ចរបស់គូភាគីក្នុងការគ្រប់គ្រងដោយឈឺឆ្អាល

## ផ្នែកទី១ ៖ ករណីយកិច្ចរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

ថ្វីត្បិតតែ អ្នកគ្រប់គ្រងដោយឈឺឆ្អាល បានចាប់ផ្តើមបំពេញកិច្ចការដើម្បីប្រយោជន៍បុគ្គលដែលត្រូវបានគេគ្រប់គ្រង (សាមីខ្លួន) ក៏ពិតមែន ក៏ប៉ុន្តែដើម្បីការពារដល់ផលប្រយោជន៍របស់សាមីខ្លួនដែលជាម្ចាស់ទ្រព្យសម្បត្តិ ឬអ្នកមានសិទ្ធិបុគ្គលដែលត្រូវបានគ្រប់គ្រង គឺច្បាប់ក៏បានតម្រូវឱ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាល បំពេញនូវករណីយកិច្ចមួយចំនួនដូចខាងក្រោម៖

### ១.ករណីយកិច្ចជូនដំណឹង

ជាគោលការណ៍អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវតែជូនដំណឹងអំពីហេតុការណ៍ដែលខ្លួនបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាលទៅឲ្យសាមីខ្លួនដោយគ្មានការយឺតយ៉ាវ។ នេះមានន័យថានៅពេលណាដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះ បានចាប់ផ្តើមសាមីខ្លួនច្រើនតែមិនដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ។[20]

ត្រង់ន័យនេះ ការគ្រប់គ្រងដោយឈឺឆ្អាល គឺជាការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង ឬបុគ្គលផ្សេងទៀតក៏ដោយ ក៏វានៅតែជាការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃដែរ។ ដើម្បីកុំឲ្យមានបាតុភាពអកម្មកើតឡើងដោយថាហេតុ។ ហេតុដូចនេះហើយ ចាំបាច់អ្នកគ្រប់គ្រងដោយការឈឺឆ្អាល ត្រូវជូនដំណឹងអំពីការបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាល ទៅឲ្យសាមីខ្លួនដោយគ្មានការយឺតយ៉ាវ។ ម្យ៉ាងវិញទៀត ក្នុងគោលបំណងឲ្យបានដឹងពីឆន្ទៈរបស់សាមីខ្លួនផង និងបង្ហាញពីភាពសុច្ចរិតនឹងការគ្រប់គ្រងរបស់ខ្លួនផង។ ប្រសិនបើសាមីខ្លួននៅឆ្ងាយ ឬមិនអាចធ្វើការទំនាក់ទំនងបានអំពីការជូនដំណឹងទេ នៅពេលសាមីខ្លួនត្រឡប់មកវិញ អ្នកគ្រប់គ្រងត្រូវជូនដំណឹងជាបន្ទាន់នៅពេលដែលសាមីខ្លួនអាចទទួលការជូនដំណឹង។

តាមន័យនេះ ការជូនដំណឹងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

**ការជូនដំណឹងត្រូវធ្វើនៅក្រោយពេលចាប់ផ្តើមគ្រប់គ្រង** មានន័យថា អ្នកគ្រប់គ្រងដោយឈឺឆ្អាលបានចាប់ផ្តើមបំពេញកិច្ចការគតិយុត្តក្នុងនាមសាមីខ្លួនរួចរាល់ហើយ។ ទើបបានធ្វើការជូនដំណឹង។ ក្នុងករណីដែលការជូនដំណឹងត្រូវបានធ្វើឡើងនៅមុនពេលចាប់ផ្តើមធ្វើការគ្រប់គ្រងនោះអាចមានស្ថានភាព ៣ យ៉ាងដែលអាចនឹងកើតមានឡើង រួមមាន៖

[20] មាត្រា ៧៣១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

### ១.១.សាមីខ្លួនបានយល់ព្រមឱ្យអ្នកគ្រប់គ្រងចាប់ផ្ដើមធ្វើការគ្រប់គ្រង

ករណីនេះ តើអាចចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលបានដែរ ឬទេ? ឧទាហរណ៍៖ លោក **ក** ជាអ្នកជិតខាងរបស់លោក **ខ** បានឃើញថាដំបូលផ្ទះរបស់លោក **ខ** បានខូចខាតដោយសារខ្យល់បក់ ខណៈដែលលោក **ខ** មិននៅផ្ទះ។ ភ្លាមនោះ លោក **ក** ក៏បានទូរស័ព្ទទៅលោក **ខ** ដើម្បីឱ្យលោក **ខ** បានដឹង។ លោក **ខ** បានស្នើសុំឱ្យលោក **ក** ជួយប្រក់ដំបូល និងថែរក្សាផ្ទះរបស់ខ្លួនផង ហើយរាល់ការចំណាយលើសោហ៊ុយផ្សេងៗ លោក **ខ** បានស្នើសុំឱ្យ លោក **ក** ចេញឱ្យសិន នៅពេលដែលខ្លួនត្រលប់មកវិញ លោក **ខ** នឹងចេញសងទាំងអស់ ហើយលោក **ក** ក៏យល់ព្រមជួយ។ ករណីនេះ លោក **ក** បានចាប់ផ្ដើមជួសជុលដំបូលផ្ទះរបស់លោក **ខ** តាមរយៈការព្រមព្រៀងរវាងលោក **ក** និងលោក **ខ**។ បើយើងធ្វើការពិនិត្យដោយយកចិត្តទុកដាក់ទៅ ការចាប់ផ្ដើមគ្រប់គ្រងបែបនេះ គឺកើតចេញពីកិច្ចសន្យា ដែលសំណើររបស់លោក **ខ** និងស្ទីកាលោក **ក** មានភាពត្រូវគ្នា។ ម៉្យាងវិញទៀត ការគ្រប់គ្រងរបៀបនេះ គឺជាលោក **ក** មានសិទ្ធិគ្រប់គ្រងដោយតាមរយៈកិច្ចសន្យា ដែលមានលក្ខណៈផ្ទុយពីលក្ខខណ្ឌនៃការគ្រប់គ្រងដោយឈឺឆ្អាល ត្រង់ថាដើម្បីចាត់ទុកថាការគ្រប់គ្រងដោយឈឺឆ្អាល ចាំបាច់អ្នកគ្រប់គ្រងគ្មានសិទ្ធិអំណាចក្នុងការគ្រប់គ្រង។ ដូច្នេះហើយ ករណីនេះមិនត្រូវចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលទេ។

### ១.២.សាមីខ្លួនបានធ្វើការបដិសេធមិនឱ្យចាប់ផ្ដើមការគ្រប់គ្រង

សំដៅស្ថានភាពមួយដែលនៅមុនពេលការគ្រប់គ្រងត្រូវបានចាប់ផ្ដើម ហើយអ្នកដែលនឹងត្រូវគ្រប់គ្រងបានជូនដំណឹងជាមុនទៅសាមីខ្លួនអំពីការចាប់ផ្ដើមគ្រប់គ្រង នៅពេលនោះសាមីខ្លួនបានធ្វើការបដិសេធអំពីការចាប់ផ្ដើមការគ្រប់គ្រងរបស់អ្នកគ្រប់គ្រង។ ក្នុងស្ថានភាពបែបនេះ អ្នកគ្រប់គ្រងអាចមិនចាប់ផ្ដើមគ្រប់គ្រងតាមសម្ដីរបស់សាមីខ្លួន ឬចាប់ផ្ដើមធ្វើការគ្រប់គ្រងដោយពិនិត្យមើលលើស្ថានភាពគ្រោះថ្នាក់ ប្រសិនបើគ្មានការគ្រប់គ្រង។ ករណីដែលអ្នកគ្រប់គ្រងមិនចាប់ផ្ដើមធ្វើការគ្រប់គ្រងទេ នោះវានឹងគ្មានបញ្ហាដែលត្រូវពិចារណាតទៅទៀតទេ ដោយហេតុថាគ្មានការចាប់ផ្ដើមសកម្មភាពគតិយុត្តណាមួយឡើយ ពោលគ្រាន់តែជាការជូនដំណឹងធម្មតានោះទេ។ ប៉ុន្តែករណីនេះដែលសាមីខ្លួនបានធ្វើការបដិសេធ មិនឱ្យអ្នកគ្រប់គ្រងចាប់ផ្ដើមធ្វើការគ្រប់គ្រង ហើយអ្នកគ្រប់គ្រងនៅតែចាប់ផ្ដើមធ្វើការគ្រប់គ្រងដោយចិត្តឯងនោះ ដោយអ្នកគ្រប់គ្រងយល់ឃើញថា ស្ថានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរនឹងអាចកើតមានឡើងដល់សាមីខ្លួន ករណីដែលគ្មានវត្តមាននៃការគ្រប់គ្រងដោយឈឺឆ្អាលទេ។ សួរថាតើ សកម្មភាពបែបនេះចាត់ទុកជាការគ្រប់គ្រងដោយឈឺឆ្អាលឬទេ?

ក្នុងករណីនេះ មិនអាចចូលក្នុងការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ ដោយខ្វះធាតុនៃការយល់ព្រម និងម្យ៉ាងទៀត ជាការបំពានដល់សេរីភាពចាត់ចែងទ្រព្យរបស់សាមីខ្លួន។ បន្ថែមពីនោះ បញ្ញត្តិក្រមរដ្ឋប្បវេណីបានបញ្ជាក់ថា ការគ្រប់គ្រងត្រូវបញ្ចប់ដោយកាលណាវាផ្ទុយទៅនឹងឆន្ទៈរបស់សាមីខ្លួន។

**១.៣.សាមីខ្លួនផ្តល់ការយល់ព្រមយឺតយ៉ាវ**

សំដៅលើស្ថានភាពមួយ ដែលអ្នកគ្រប់គ្រងបានជូនដំណឹងអំពីស្ថានភាព ឬហេតុការណ៍គ្រោះថ្នាក់ដល់សាមីខ្លួនរួចហើយ ប៉ុន្តែសាមីខ្លួន មិនទាន់បានផ្តល់ការយល់ព្រមឱ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាល ចាប់ផ្តើមធ្វើការគ្រប់គ្រងទេ ពោល គឺសាមីខ្លួនមានការយឺតយ៉ាវក្នុងការផ្តល់ការយល់ព្រមអំពីការចាប់ផ្តើមការគ្រប់គ្រង។ ស្ថានភាពបែបអ្នកគ្រប់គ្រង នៅតែចាប់ផ្តើមធ្វើការគ្រប់គ្រង សួរថាសកម្មភាពបែបនេះចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលឬទេ?

បើយោងតាមខ្លឹមសារនៃមាត្រា ៧៣១ នៃក្រមរដ្ឋប្បវេណី កម្មវត្ថុដែលត្រូវជូនដំណឹងនោះគឺ "ការបានចាប់ផ្តើមការគ្រប់គ្រងឈឺឆ្អាល"។ "ការបានចាប់ផ្តើមគ្រប់គ្រងដោយឈឺឆ្អាល" មកពីការផ្សំបញ្ចូលគ្នារវាង "ការបាន" និង "ចាប់ផ្តើមគ្រប់គ្រងដោយឈឺឆ្អាល"។ "ការបាន" សំដៅលើស្ថានភាពបញ្ជាក់ពីអតីតកាល មានន័យថា សកម្មភាពណាមួយបានកន្លងហួសទៅហើយ។ ដូច្នេះ ការជូនដំណឹងអំពី "ការបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាល" គឺសំដៅលើការជូនដំណឹងអំពីការចាប់ផ្តើមគ្រប់គ្រងដោយឈឺឆ្អាល ដែលបានបំពេញរួចហើយ។

អ្នកទទួលការជូនដំណឹងគឺមានតែសាមីខ្លួនតែប៉ុណ្ណោះ៖ សាមីខ្លួន មានន័យដូចម្តេច?

**សាមីខ្លួននេះ អាចត្រូវបានធ្វើការបកស្រាយដូចខាងក្រោម៖**

- **ចំពោះការគ្រប់គ្រងលើទ្រព្យ៖** សាមីខ្លួននេះ សំដៅលើបុគ្គលដែលមានសិទ្ធិលើទ្រព្យ ពោលគឺមានសិទ្ធិប្រត្យក្សលើទ្រព្យ ដែលជាកម្មវត្ថុនៃការគ្រប់គ្រងដោយឈឺឆ្អាលនោះ ដូចជាកម្មសិទ្ធិករនៃទ្រព្យ អ្នកកាន់កាប់ទ្រព្យ ផលុបភោគី...។ល។
- **ចំពោះការគ្រប់គ្រងលើមនុស្ស៖** សាមីខ្លួននេះ សំដៅលើបុគ្គល ដែលមានសិទ្ធិលើបុគ្គលនោះតាមរយៈ អ្នកតំណាងតាមច្បាប់កំណត់ និង ហិតូបត្ថម្ភកៈ។
- **មានន័យថា៖** សាមីខ្លួន សំដៅដល់បុគ្គលដែលទទួលផលប្រយោជន៍ ឬ បុគ្គលដែលទ្រព្យរបស់ខ្លួនត្រូវបានគេគ្រប់គ្រង។

ក្នុងករណីដែលអ្នកគ្រប់គ្រងដោយឈឺឆ្អាល មិនបានស្គាល់សាមីខ្លួនទេ អ្នកគ្រប់គ្រងដោយឈឺឆ្អាល មិនចាំបាច់ធ្វើការជូនដំណឹងនេះទេ ពោលគឺនៅតែបន្តការគ្រប់គ្រងតទៅទៀត។

ការជូនដំណឹងត្រូវធ្វើឡើងដោយគ្មានការយឺតយ៉ាវ៖ "**គ្មានការយឺតយ៉ាវ**" អាចត្រូវបានវិនិច្ឆ័យយ៉ាងដូចម្ដេច?

ការយឺតយ៉ាវ ឬគ្មានការយឺតយ៉ាវ អាចត្រូវធ្វើការវិនិច្ឆ័យតាមលក្ខណៈនៃការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល។ ប្រសិនបើកិច្ចការដែលត្រូវបានគ្រប់គ្រងនោះ គឺជាកិច្ចការតែមួយផង អ្នកគ្រប់គ្រងហាក់ដូចជាមិនចាំបាច់ធ្វើការដំណឹងទេ។ ប៉ុន្តែ អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវមានករណីយកិច្ចរាយការណ៍នៅចុងបញ្ចប់ អ្នកគ្រប់គ្រងត្រូវតែជូនដំណឹងទៅសាមីខ្លួន ទោះបីជាកិច្ចការតែមួយដងក៏ដោយ។[21] ដើម្បីបញ្ជាក់ពីគ្មានភាពយឺតយ៉ាវនៃការជូនដំណឹងនេះ អ្នកគ្រប់គ្រងត្រូវធ្វើការជូនដំណឹងទៅសាមីខ្លួន តាមគ្រប់មធ្យោបាយ តាមលទ្ធភាពដែលអាចធ្វើទៅបានក្នុងការជូនដំណឹងទៅសាមីខ្លួននេះ លើកលែងតែសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនោះហើយ ការជូនដំណឹងនេះ មិនចាំបាច់ឡើយ។[22] អានុភាពនៃការជូនដំណឹង ៖ កាលណាសាមីខ្លួនទទួលបាននូវដំណឹងពីកិច្ចការគ្រប់គ្រងរបស់អ្នកគ្រប់គ្រង បញ្ញត្តិស្ដីពីការអាណត្តិត្រូវយកមកអនុវត្តដូចគ្នា។

**២.ករណីយកិច្ចបន្តការគ្រប់គ្រង**

ប្រសិនបើអ្នកគ្រប់គ្រងបានធ្វើការគ្រប់គ្រងហើយ តែសាមីខ្លួនមិនទាន់ត្រឡប់មកវិញ ឬក៏មិនអាចទាន់គ្រប់គ្រងបានទេ នោះអ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវបន្តការគ្រប់គ្រងនោះតទៅទៀតក្នុងន័យការពារ និងធ្វើឲ្យបានប្រយោជន៍ដល់សាមីខ្លួនដដែល រហូតដល់ពេលដែលសាមីខ្លួន ឬទាយាទ ឬអ្នកតំណាងដែលកំណត់ដោយច្បាប់របស់សាមីខ្លួនអាចធ្វើការគ្រប់គ្រងវិញបាន។[23] ប៉ុន្តែក៏មានករណីលើកលែងផងដែរ ប្រសិនបើការបន្តការគ្រប់គ្រងផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬធ្វើឲ្យខូចប្រយោជន៍ចំពោះសាមីខ្លួន។[24]

ឧទាហរណ៍៖ លោក **ក** ដែលកំពុងជួសជុល និងថែរក្សាផ្ទះឱ្យលោក **ខ** នោះតាមរយៈការគ្រប់គ្រងដោយឈឺឆ្អាលនោះ។ នៅពេលដែលលោក **ខ** មិនបានមកដល់ ឬមិនអាចគ្រប់គ្រងបន្តបាន នោះលោក **ក** នៅតែមានករណីយកិច្ចបន្តការគ្រប់គ្រងដើម្បីផលប្រយោជន៍របស់លោក **ខ** ដដែល។

[21] ដោយយោងតាមបញ្ញត្តិស្ដីពីអាណត្តិ មាត្រា ៦៤១ នៃក្រមរដ្ឋប្បវេណី

[22] មាត្រា ៧៣១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[23] មាត្រា ៧៣២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[24] មាត្រា ៧៣២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

តាមន័យនេះ អ្នកគ្រប់គ្រង នៅតែបន្តការគ្រប់គ្រងកម្មវត្ថុនៃការគ្រប់គ្រងដោយឈឺឆ្អាលដដែលរហូតដល់ ពេលការគ្រប់គ្រងត្រូវបានបញ្ចប់។ ការគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបានបញ្ចប់ដូចខាងក្រោម៖

- **សាមីខ្លួន ឬសន្តតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់សាមីខ្លួននោះអាចធ្វើការគ្រប់គ្រងបាន** មានន័យថា ទោះបីជាសាមីខ្លួន ឬសន្តតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់សាមីខ្លួន បានដឹង ឬបានមកដល់ក៏ដោយ ក៏អ្នកគ្រប់គ្រងដោយឈឺឆ្អាលនៅតែបន្តការគ្រប់គ្រងដដែល លុះត្រាតែជនទាំងនោះ អាចធ្វើការគ្រប់គ្រងបាន។

ឧទាហរណ៍ទី១៖ (ការជួសជុលផ្ទះរបស់លោក **ខ** ដោយលោក **ក** ខាងលើ) នៅពេលដែលលោក **ខ** ដែលជាសាមីខ្លួនបានមកដល់ផ្ទះរបស់ខ្លួន ហើយឃើញលោក **ក** ជួសជុលផ្ទះឱ្យខ្លួនបែបនេះ ខ្លួនសប្បាយចិត្តជាខ្លាំងជាមួយនឹងលោក **ក** ដែលបានជួយយកអាសារគាត់។ ពេលនោះលោក **ខ** ក៏បានចូលមករស់នៅ និងចេញសោហ៊ុយជូនលោក **ក**។ តើលោក **ខ** អាចគ្រប់គ្រងបានឬនៅ?

ឧទាហរណ៍ទី២៖ (ផ្ទុយនឹងឧទាហរណ៍ខាងលើ) នៅពេលដែលលោក **ខ** ឃើញដូចនោះខ្លួនបានការមិនសប្បាយចិត្តជាមួយនឹងលោក **ក** ដែលបានជួសជុលផ្ទះរបស់ខ្លួន ដោយគ្មានការប្រុងប្រយ័ត្ន និង ខ្លួនមិនពេញចិត្ត។ ពេលនោះលោក **ខ** ក៏បានបង្ហាញឆន្ទៈទៅកាន់លោក **ក** ថាខ្លួនមិនចូលនៅទេ ប្រសិនបើលោក **ក** មិនជួសជុលឱ្យស្អាតជាងនេះ។ ករណីនេះ តើលោក **ខ** អាចគ្រប់គ្រងបាន ឬនៅ?

ឧទាហរណ៍ទី៣៖ (ការជួសជុលផ្ទះរបស់លោក **ខ** ដោយលោក **ក** ខាងលើ) ខណៈពេលដែលលោក **ក** កំពុងជួសជុល ស្រាប់តែលោក **ខ** បានមកដល់។ ប៉ុន្តែលោក **ក** មិនទាន់បានជួសជុលរួចរាល់នោះទេ ហើយផ្ទះនោះក៏មិនអាចចូលមកស្នាក់នៅបានដែរ ដែលជាហេតុធ្វើឱ្យលោក **ខ** និងគ្រួសារស្នាក់នៅផ្ទះរបស់លោក **ក** ជាបណ្តោះអាសន្ន។ ករណីនេះ តើលោក **ខ** អាចគ្រប់គ្រងបានឬនៅ?

ឧទាហរណ៍ទី៤៖ លោក **ខ** ក្លាយជាជនដែលវិបត្តិស្មារតី ដែលខ្លួនមិនអាចធ្វើការគ្រប់គ្រងបានទេ។ នីតិវិធីនៃការជ្រើសរើសអ្នកអាណាព្យាបាលទូទៅ ឬហិតូបត្ថកៈ អាស្រ័យទៅតាមស្ថានភាពនៃលោក **ខ** ត្រូវបានចាប់ផ្តើមតាមផ្លូវតុលាការ។ អំឡុងពេលនោះ លោក **ក** នៅតែបន្តការគ្រប់គ្រងដដែល។ ក្រោយពីការជ្រើសរើសអ្នកអាណាព្យាបាលទូទៅ ឬហិតូបត្ថកៈ របស់លោក **ខ** រួចមក អ្នកអាណាព្យាបាលទូទៅ ឬហិតូបត្ថកៈរបស់លោក **ខ** បានធ្វើការគ្រប់គ្រងផ្ទះរបស់លោក **ខ** ដែលស្ថិត

នៅក្រោមការគ្រប់គ្រងដោយឈឺឆ្អាលរបស់លោក **ក**។ សួរថា តើអាណាព្យាបាលទូទៅរបស់លោក **ខ** អាចគ្រប់គ្រងបានឬនៅ? ក្នុងករណីលោក **ខ** ស្ថិតនៅក្នុងស្ថានភាពហិតូបម្ភកវិញ ដែលលោក **ខ** មិនអាចគ្រប់គ្រងបានសួរថាតើ ហិតូបម្ភកៈ អាចគ្រប់គ្រងជំនួសលោក **ខ** បានដែរឬទេ ខណៈដែលច្បាប់បានចែងត្រឹមតែ អ្នកតំណាងដែលច្បាប់បានកំណត់(ហិតូបម្ភកៈ មិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់នោះទេ)?

ឧទាហរណ៍ទី៥៖ ករណីដែលលោក **ខ** ទទួលមរណភាពមក សន្តតិជនលោក **ខ** នឹងធ្វើការគ្រប់គ្រងបន្តពីលោក **ក**។ សួរថា សន្តតិជនរបស់លោក **ខ** អាចធ្វើការគ្រប់គ្រងបាននៅពេលណា? ចុះករណីដែលសន្តតិជនរបស់លោក **ខ** ជាជនបរទេស សួរថា តើសន្តតិជនរបស់លោក **ខ** នោះអាចគ្រប់គ្រងបាននៅពេលណា? ប្រសិនបើករណីដែលលោក **ខ** គ្មានសន្តតិជនវិញ ហើយយើងបានដឹងថា អ្នកដែលទទួលសន្តតិកម្មពីលោក **ខ** ចុងក្រោយគេគឺ រដ្ឋ។ សួរថា អំឡុងពេលនៃនីតិវិធីនៃសន្តតិកម្មតាមផ្លូវតុលាការនោះ តើលោក **ក** នៅតែបន្តការគ្រប់គ្រងដែរឬយ៉ាងណា?

- **ការបន្តការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន៖** មានន័យថា សាមីខ្លួនគ្មានឆន្ទៈឱ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាលបន្តការគ្រប់គ្រងកិច្ចការរបស់ខ្លួនបន្តទៀតបានទេ ករណីនេះសាមីខ្លួនអាចមានបំណងចង់គ្រប់គ្រងដោយខ្លួនឯងវិញ ឬអាចមានបំណង់ចង់ឱ្យតតិយជនធ្វើការគ្រប់គ្រងជំនួយឱ្យអ្នកគ្រប់គ្រងក្នុងមានសាមីខ្លួន។
- **ការបន្តការគ្រប់គ្រងនោះ នឹងអាចធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួន៖** មានន័យថា អាចប៉ាន់ប្រមាណទុកជាមុនថា ប្រសិនបើអ្នកគ្រប់គ្រងនៅតែបន្តការគ្រប់គ្រងតទៅទៀតនោះ ប្រាកដជានឹងមានការបាត់បង់នូវទ្រព្យសម្បត្តិ ឬខូចប្រយោជន៍របស់សាមីខ្លួន ដែលបង្កឡើងដោយអ្នកគ្រប់គ្រងជាមិនខាន ករណីនេះ ការគ្រប់គ្រងដោយឈឺឆ្អាលរបស់អ្នកគ្រប់គ្រងត្រូវបានបញ្ចប់។

គួរគូសបញ្ជាក់ថា បុគ្គលដែលទទួលប្រយោជន៍ (សាមីខ្លួន) នៅទីនេះ គឺបញ្ញត្តិតាមក្រមរដ្ឋប្បវេណីបានកំណត់ត្រឹមតែបុគ្គល បី ប្រភេទប៉ុណ្ណោះ គឺសាមីខ្លួន សន្តតិជន និងអ្នកតំណាងដែលច្បាប់បានកំណត់របស់សាមីខ្លួន ផ្ទុយទៅវិញបាត់ពាក្យថា សហព័ន្ធ របស់សាមីខ្លួន ឬញាតិរបស់សាមីខ្លួនដូចនេះ តើគេអាចដឹងសន្និដ្ឋានថា ការបន្ត ឬបញ្ចប់ការគ្រប់គ្រងមានអានុភាពត្រឹមកម្រិតបុគ្គល បី ប្រភេទ ដែលអាចឲ្យអ្នកគ្រប់គ្រង បន្តការគ្រប់គ្រង ឬបញ្ចប់ការគ្រប់គ្រង។ ហេតុនេះបើធ្វើការបកស្រាយបែបនេះ គឺផ្ទុយទៅនឹងបញ្ញត្តិស្តីពីករណីសហការរួមរបស់សហព័ន្ធក្នុងជីវភាពប្រចាំថ្ងៃ (ចំពោះទំនាក់ទំនងសាមីខ្លួន និងសហព័ន្ធរបស់សាមីខ្លួន)។ ហើយចំពោះករណី ទំនាក់ទំនងញាតិ

របស់សហព័ន្ធវិញ ការដែលមិនបានចែងដូចនេះ ហាក់ដូចជាផ្ទុយទៅ គោលគំនិតនៃការឈឺឆ្អាល ជួយគ្នាក្នុងសង្គម ហើយដែលក្នុងសង្គមខ្មែរទំនាក់ទំនងញាតិគឺជាបញ្ហាសំខាន់ ដែលគេអាចដឹងជាទូទៅថាញាតិរបស់សាមីខ្លួនអាចមានលទ្ធភាពជួយគ្រប់គ្រងកិច្ចការនោះបាន។ ជាគំនិតរបស់យើងខ្ញុំ មាត្រា ៧៣២ គួរចែងថា "អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបន្តការគ្រប់គ្រងនោះរហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកដែលមានទំនាក់ទំនងតាមផ្លូវច្បាប់របស់ខ្លួន" ទើបគ្របដណ្តប់ចំពោះទំនាក់ទំនងខ្លឹមសារដែលមានក្នុងមាត្រានេះ ម៉្យាងដើម្បីអាចកំណត់ពីទំហំនៃបុគ្គល ដែលពាក់ព័ន្ធតាមច្បាប់កំណត់មានសិទ្ធិទទួលនូវកិច្ចការគ្រប់គ្រងបន្តពីអ្នកគ្រប់គ្រង។

### ៣.ករណីយកិច្ចប្រគល់កម្មវត្ថុនៃការគ្រប់គ្រងទៅម្ចាស់ទ្រព្យវិញ

អ្នកគ្រប់គ្រងត្រូវប្រគល់ទ្រព្យសម្បត្តិ ដែលខ្លួនទទួលបានតាមការចាត់ចែងជំនួសម្ចាស់ទ្រព្យនៅពេលមានហេតុការណ៍កើតឡើងនោះ ក្រោយពីបានគ្រប់គ្រងរួចរាល់ហើយ រហូតដល់ម្ចាស់ទ្រព្យមកដល់វិញ គឺអ្នកគ្រប់គ្រងមានករណីយកិច្ចត្រូវតែប្រគល់ការគ្រប់គ្រងទៅឲ្យម្ចាស់ទ្រព្យវិញ។[25]

តាមខ្លឹមសារនេះ មានន័យថា នៅពេលដែលការគ្រប់គ្រងត្រូវបានបញ្ចប់ អ្នកគ្រប់គ្រងមានករណីយកិច្ចត្រូវ ប្រគល់ទៅឱ្យសាមីខ្លួនវិញនូវ៖

- **ប្រាក់ និងទ្រព្យផ្សេងទៀតដែលបានមកពីការគ្រប់គ្រង៖** ឧទាហរណ៍៖ នៅអំឡុងពេលនៃការគ្រប់គ្រង អ្នកគ្រប់គ្រងបានទទួលនូវប្រាក់ និង ទ្រព្យមួយចំនួន តាមរយៈការគ្រប់គ្រងនូវកិច្ចការនោះ ករណីនេះ អ្នកគ្រប់គ្រងមានករណីយកិច្ចត្រូវប្រគល់ប្រាក់ និងទ្រព្យដែលខ្លួនបានទទួលទៅឱ្យសាមីខ្លួនវិញ នៅពេលបញ្ចប់ការគ្រប់គ្រង។
- **ផល (ផលស៊ីវិល និងផលធម្មជាតិ) ដែលអ្នកគ្រប់គ្រងបានទទួលតាមរយៈការគ្រប់គ្រងកិច្ចការនោះ៖** អ្នកគ្រប់គ្រងត្រូវប្រគល់ផលនោះ ទៅឱ្យសាមីខ្លួននៅពេលបញ្ចប់ការគ្រប់គ្រង។
- **សិទ្ធិដែលបានលទ្ធកម្មដើម្បីសាមីខ្លួន ក៏ត្រូវប្រគល់ទៅឱ្យសាមីខ្លួនវិញដែរ** នៅពេលបញ្ចប់ការគ្រប់គ្រង។

### ៤.ករណីយកិច្ចរាយការណ៍

ការគ្រប់គ្រងដោយឈឺឆ្អាល គឺមានលក្ខណៈស្រដៀងគ្នាទៅនឹងអាណត្តិដែរ ហើយមានកាតព្វកិច្ចដូចគ្នា ត្រូវធ្វើដើម្បីជាប្រយោជន៍របស់សាមីខ្លួន និងជូនដំណឹងអំពីកិច្ចសន្យាផ្សេងៗដែលខ្លួនគ្រប់គ្រង។ អ្នកគ្រប់គ្រងនេះត្រូវរាយការណ៍អំពីស្ថានភាពនៃកិច្ចការចាត់ចែងរបស់ខ្លួនទៅម្ចាស់

[25] មាត្រា ៦៩២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ទ្រព្យ ទោះបីជាពេលណាក៏ដោយ ឬត្រូវរាយការណ៍អំពីហេតុការណ៍នោះដោយគ្មានយឺតយ៉ាវនៅក្រោយពេលដែលបានបញ្ចប់ហេតុការណ៍នោះ ជូនម្ចាស់ទ្រព្យសម្បត្តិ។[26]

នៅក្នុងស្ថានភាពមួយដែល សាមីខ្លួន មានការបារម្ភអំពីការគ្រប់គ្រង របស់អ្នកគ្រប់គ្រង ដូចជាសាមីខ្លួនមានការបារម្ភថា អ្នកគ្រប់គ្រង បានគ្រប់គ្រងដោយមានចេតនាទុច្ចរិត ឬការធ្វេសប្រហែស ឬបណ្តាលឱ្យមានព្យសនកម្មណាមួយបានកើតឡើង ទើបសាមីខ្លួនអាចស្នើឱ្យអ្នកគ្រប់គ្រងធ្វើការរាយការណ៍អំពីហេតុការណ៍នៃការគ្រប់គ្រងឱ្យមកខ្លួន។ ករណីនេះ អ្នកគ្រប់គ្រងត្រូវមានករណីយកិច្ចដូចខាងក្រោម៖

- ត្រូវរាយការណ៍អំពីស្ថានភាពនៃការគ្រប់គ្រងកិច្ចការ ឬ អំពីភាពនៃការគ្រប់គ្រងកិច្ចការ ឬ អំពីហេតុការណ៍។
- ត្រូវរាយការណ៍គ្រប់ពេលវេលា៖ មានន័យថា អ្នកគ្រប់គ្រង ត្រូវរាយការណ៍ភ្លាមនៅពេលដែលមានការទាមទារពីសាមីខ្លួន។
- ត្រូវរាយការណ៍ដោយគ្មានការយឺតយ៉ាវ។

**៥.ករណីយកិច្ចទាមទារសំណងចំពោះប្រាក់ដែលបានចំណាយ**

ម្យ៉ាងទៀត បើមានការខូចខាតដែលមិនមែនបណ្តាលមកពីកំហុសរបស់អ្នកគ្រប់គ្រងនៅក្នុងការចាត់ចែងកិច្ចការនោះទេ អ្នកគ្រប់គ្រងក៏នៅតែមានករណីយកិច្ចអាចទាមទារសំណងនោះពីម្ចាស់ទ្រព្យបានដដែរ។ ទោះបីជាការខូចខាតនោះ កើតឡើងដោយចេតនា ឬកំហុសរបស់តតិយជនក៏ដោយ ក៏អ្នកគ្រប់គ្រងអាចទាមទារសំណងចំពោះម្ចាស់ទ្រព្យបានត្រឹមកម្រិត ដែលពុំបានទទួលសំណងពីតតិយជននោះទេ។[27]

**៦.ករណីយកិច្ចគ្រប់គ្រងដោយផ្អែកតាមឆន្ទៈរបស់សាមីខ្លួន ឬ តាមវិធីសមរម្យ**

ក្នុងករណីដែលអ្នកគ្រប់គ្រងដោយឈឺឆ្អាលបានដឹង ឬ អាចដឹងអំពីឆន្ទៈរបស់សាមីខ្លួន (សាមីខ្លួន) នោះអ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវធ្វើការគ្រប់គ្រង ដោយផ្អែកតាមឆន្ទៈរបស់បុគ្គលដែលជាសាមីខ្លួននោះ។ ករណីដែលមិនបានដឹងទេ អ្នកគ្រប់គ្រងដោយឈឺឆ្អាលត្រូវធ្វើការគ្រប់គ្រងដោយព្យាយាម ដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាងគេដើម្បីប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការ មានន័យថាការគ្រប់គ្រងកិច្ចការដោយមានការយកចិត្តទុកដាក់ខ្ពស់ ដែលអ្នកប្រកបដោយវិចារណញ្ញាណនឹងធ្វើ ក្នុងស្ថានភាព

[26] មាត្រា ៦៤១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[27] មាត្រា ៦៤៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ជាក់លាក់មួយ។ ការគ្រប់គ្រងដោយផ្ទុយពីឆន្ទៈរបស់សាមីខ្លួន ត្រូវបញ្ឈប់ការគ្រប់គ្រងជាបន្ទាន់ លើកលែងតែក្នុងស្ថានភាពពិសេស ដែលការរង់ចាំនឹងបង្កនូវការខូចខាតដល់ផលប្រយោជន៍របស់សាមីខ្លួន។ អ្នកគ្រប់គ្រងបានដឹងពីថាធ្វើឲ្យខូចប្រយោជន៍ ឬផ្ទុយពីឆន្ទៈរបស់ខ្លួន។ ក៏ប៉ុន្តែផ្អែកតាមក្រមរដ្ឋប្បវេណីប្រទេសថៃបានអនុញ្ញាតឲ្យបន្តការគ្រប់គ្រងណាដែលការគ្រប់គ្រងនោះដើម្បីប្រយោជន៍សាធារណៈ ហើយដែលមិនអាចរំពឹងថា សាមីខ្លួននឹងមកធ្វើកិច្ចការនោះទាន់ពេលវេលាដែរ។ ត្រង់ចំណុចនេះ ក្រមរដ្ឋប្បវេណីបានផ្តល់អាទិភាពដល់ផលប្រយោជន៍សាធារណៈធំ ជាងផលប្រយោជន៍ឯកជន បើទោះណាជាអ្នកគ្រប់គ្រងបានដឹងថាផ្ទុយពីឆន្ទៈរបស់សាមីខ្លួនក៏ដោយ។

## ផ្នែកទី២ ករណីយកិច្ចរបស់អ្នកត្រូវគេគ្រប់គ្រង (សាមីខ្លួន)

### ១.ករណីយកិច្ចប្រគល់សោហ៊ុយលើការគ្រប់គ្រង

ក្នុងករណី ដែលអ្នកគ្រប់គ្រងបានបំពេញសកម្មភាពជាប្រយោជន៍ដល់ម្ចាស់ទ្រព្យក្នុងការចំណាយលើសម្ភារៈផ្សេងៗ ក្នុងគោលបំណងការពារផលប្រយោជន៍។ សបញ្ជាក់ថាភាពមានទំនាក់ទំនងជួយគ្នាទៅវិញទៅមកដើម្បីស្ថាបនា ឬក៏ជួយផ្គត់ផ្គង់គ្នាក្នុងគ្រាមានអាសន្ន។ ហេតុដូច្នេះទើបច្បាប់បានកំណត់ឲ្យមានករណីយកិច្ច លើម្ចាស់ទ្រព្យត្រូវប្រគល់សងនូវរាល់ការចំណាយទៅឲ្យអ្នកគ្រប់គ្រងវិញ តាមភាពជាក់ស្តែងដែលបានកើតឡើង។

ឧទាហរណ៍៖ **ក** ឃើញស្ថានភាពផ្ទះធ្លុះដំបូលស័ង្កសី ដោយស្ថានភាព **ខ** មិននៅផ្ទះ។ **ក** សុំយោបល់ពី **ខ** ថាខ្លួនជួយជួសជុលដំបូលផ្ទះឲ្យ ហើយ **ខ** ក៏យល់ព្រមតាមសំណើររបស់ **ក** ក្នុងគោលបំណងការពារទ្រព្យសម្បត្តិរបស់ខ្លួនកុំឲ្យខូចខាតដោយសារទឹកភ្លៀង។ ទើប **ក** ទិញស័ង្កសីថ្មីមកប្រក់ចំនួន ៥សន្លឹក ដូចមានបញ្ជាក់ក្នុងវិក័យបត្រស្រាប់។

ប៉ុន្តែក្នុងករណីនេះ គេមិនគិតថ្លៃសេវា ឬវិជ្ជាជីវៈផ្សេងៗបញ្ចូលគ្នាដូចកម្រៃទេ។

### ២.ករណីយកិច្ចប្រគល់កម្រៃ

ចំពោះបញ្ហានេះ សាមីខ្លួនមានករណីយកិច្ចត្រូវប្រគល់កម្រៃដល់អ្នកគ្រប់គ្រង នៅពេលដែលខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះដែរ រួមទាំងវិជ្ជាជីវៈ ឬអាជីវកម្មរបស់អ្នកគ្រប់គ្រងចំពោះកិច្ចការនោះ។ ចំនុចនេះមានន័យថា បន្ទាប់ពីអ្នកគ្រប់គ្រងបានជួសជុសជំនួសខ្លួនហើយនោះ អ្នកគ្រប់គ្រងមិនត្រឹមតែទទួលត្រឡប់មកវិញនូវរាល់ការចំណាយរបស់ខ្លួនប៉ុណ្ណោះទេ។ ហើយគាត់ក៏អាចទទួលនូវការលើកទឹកចិត្តពីបេសកកម្មនេះបានដែរ។

### ៣.ករណីយកិច្ចគិតអត្រាការប្រាក់ចំពោះការយឺតយ៉ាវ

ប្រសិនបើម្ចាស់ទ្រព្យ គាត់បានដឹងអំពីការចំណាយ ឬ ការបង្កើនតម្លៃនៃទ្រព្យរបស់ខ្លួន ហើយ នៅពេលដែលអ្នកគ្រប់គ្រងមានការទាមទារនូវការចំណាយនោះត្រឡប់មកវិញ ប៉ុន្តែម្ចាស់

ទ្រព្យមានការយឺតយ៉ាវក្នុងការអនុវត្តករណីយកិច្ចរបស់ខ្លួនមិនបាន ហើយធ្វើឲ្យមានការពន្យាពេលនៃការប្រគល់សងនេះតាមការកំណត់ហើយនោះ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីបានកំណត់អំពីការយឺតយ៉ាវដោយគិតអត្រាការប្រាក់តាមច្បាប់កំណត់ ប្រសិនបើគ្មានការព្រមព្រៀងគ្នាពីការប្រាក់ទេ គឺក្នុងគោលបំណងការពារសិទ្ធិ និងផលប្រយោជន៍របស់អ្នកជួយខ្លួនដោយឥតប្រយោជន៍។[28]

ឧទាហរណ៍៖ លោក **ក** បានដឹងអំពីការគ្រប់គ្រង និងការចំណាយផ្សេងៗលោក **ខ**។ ហើយបានយល់ព្រមទទួលស្គាល់ចំពោះការសងនូវការចំណាយផ្សេងៗ ដែលបានធ្វើឡើងក្នុងអំឡុងពេលនៃការគ្រប់គ្រងដោយឈឺឆ្អាល។ ប៉ុន្តែលោក **ក** រវល់ទៅប្រទេសក្រៅមួយរយៈពេលធំ ចំណែកលោក **ខ** ដែលបានចំណាយប្រាក់ផ្ទាល់ខ្លួនដើម្បីជួយសង្គ្រោះផ្ទះរបស់លោក **ក** គឺខាតបង់ប្រាក់ និងពេលវេលាផ្ទាល់ខ្លួនផង។ ដូច្នេះ លោក **ខ** អាចសុំទាមទារឲ្យលោក **ខ** គិតការប្រាក់ចំពោះការសងមកយឺតយ៉ាវមកខ្លួន ក្នុងសកម្មភាពចំណាយលើការគ្រប់គ្រងនោះ។

ម្យ៉ាងទៀត បើគូភាគីមិនបានគិតអត្រាការប្រាក់ដោយខ្លួនឯងទេ គឺគូភាគីជ្រើសរើសអត្រាការប្រាក់តាមច្បាប់កំណត់បាន។ មានន័យថា ជាការលើកទឹកចិត្តដល់ជនដែលជួយឈឺឆ្អាលការពារផលប្រយោជន៍អ្នកដទៃ ដែលមិនមែនជាផលប្រយោជន៍របស់ខ្លួន។

[28] មាត្រា ៣១៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

# ជំពូកទី៣

# សិទ្ធិរបស់គូភាគីក្នុងការគ្រប់គ្រងដោយឈឺឆ្អាល

## ផ្នែកទី១ ៖ សិទ្ធិរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

ការដាក់បន្ទុកដោយផ្អែកលើការត្រិះរិះពិចារណាមើលថា ដូចគ្នានឹងករណីយកិច្ចធ្វើសេចក្តីរាយការណ៍ផងដែរ ក្នុងការចំណាយប្រាក់ដែលទទួលស្គាល់ថាជាចាំបាច់សម្រាប់ធ្វើការចាត់ចែងការងារនោះ គឺអ្នកគ្រប់គ្រងអាចទាមទារ ចំពោះម្ចាស់ទ្រព្យឲ្យសងមកវិញ នូវសោហ៊ុយ និងការប្រាក់បាន ដោយគិតចាប់ពីក្រោយថ្ងៃដែលបានចំណាយសោហ៊ុយនោះ។

ប្រសិនបើបានទទួលបន្ទុកកាតព្វកិច្ចដែលទទួលស្គាល់ថា ចាំបាច់សម្រាប់ធ្វើការចាត់ចែងកិច្ចការដែលខ្លួនបានធ្វើនោះ អ្នកគ្រប់គ្រងក៏អាចឲ្យម្ចាស់ទ្រព្យសងកាតព្វកិច្ចនោះជំនួសខ្លួន និងបើពុំទាន់ដល់កំណត់ពេលដែលត្រូវសងកាតព្វកិច្ចនោះទេ អាចឲ្យដាក់ប្រាតិភោគដែលសមរម្យបាន។

### កថាភាគទី១ ៖ សិទ្ធិទាមទារសោហ៊ុយរបស់អ្នកគ្រប់គ្រង

#### ១.សិទ្ធិទាមទាររបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

ក្នុងករណីនេះ អាណត្តិគាហកសំដៅលើអ្នកដែលធ្វើការចាត់ចែងគ្រប់គ្រង ដើម្បីផលប្រយោជន៍ម្ចាស់ទ្រព្យ ដែលគេបានជួយផ្តាំផ្ញើ ឬពឹងពាក់ឲ្យមើលការខុសត្រូវរយៈពេលណាមួយ។ ប៉ុន្តែ ក្នុងន័យការគ្រប់គ្រងដោយឈឺឆ្អាលនេះ ប្រសិនបើអាណត្តិគាហកបានចំណាយប្រាក់ដែលខ្លួនទទួលស្គាល់ថាចាំបាច់ក្នុងការចាត់ចែងកិច្ចការអាណត្តិ ក្នុងគ្រាមួយដែលមានការយល់ព្រមពីម្ចាស់ទ្រព្យ។ ក្រោយពីការបញ្ចប់កិច្ចការរួចអស់ អាចឲ្យម្ចាស់ទ្រព្យសងមកវិញនូវសោហ៊ុយ និងការប្រាក់បាន ដោយគិតចាប់ពីក្រោយថ្ងៃដែលបានចំណាយសោហ៊ុយ។[29]

#### ២.សិទ្ធិទាមទារការចំណាយបង្កើនតម្លៃ

ការចំណាយចាំបាច់ក្នុងពេលគ្រប់គ្រង គឺជាការចំណាយមួយដែលធ្វើក្នុងគោលដៅបញ្ចៀសនូវរាល់បញ្ហាជាបណ្តោះអាសន្ន ចំពោះវត្ថុដែលត្រូវគ្រប់គ្រងក្នុងភាពបន្ទាន់ ។ មានន័យថា ជាការចំណាយ ដោយខានពុំបានដែលជាបន្ទុករបស់អ្នកគ្រប់គ្រង ចាំបាច់ត្រូវចំណាយក្នុងការជួយសង្គ្រោះនូវហេតុការណ៍ដែលបានកើតឡើង និងកំពុងនឹងកើតមានឡើងនេះ។ ម្យ៉ាងវិញទៀត ក្នុងគោលបំណងកែលម្អ ឬការពារលើទ្រព្យសម្បត្តិ ដើម្បីបញ្ចប់នូវហេតុការណ៍នេះ។ អ្នកគ្រប់គ្រងដោយឈឺឆ្អាលមានសិទ្ធិទាមទារឲ្យសងរាល់ការចំណាយចាំបាច់ពីម្ចាស់ទ្រព្យបាន។

[29] មាត្រា ៧៣៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

ប្រសិនបើបានចំណេញជាចាំបាច់សម្រាប់ការគ្រប់គ្រង និងថែរក្សាទ្រព្យ ឬចំណាយបង្កើនតម្លៃដើម្បីសាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទារ ចំពោះសាមីខ្លួនឲ្យសងវិញបាន ។[30] តាមខ្លឹមសារនៃបញ្ញត្តិនេះ អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារឲ្យសាមីខ្លួន សងនូវសោហ៊ុយដែលខ្លួនបានចំណាយ នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារឲ្យសាមីខ្លួនសងនូវសោហ៊ុយដែលខ្លួនបានចំណាយ នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងនោះវិញបានលុះត្រាតែ៖

**២.១.សោហ៊ុយចំណាយចាំបាច់**

តើភាពចាំបាច់នៃការចំណាយនោះអាចបានត្រូវវិនិច្ឆ័យដោយរបៀបណា? ឧទាហរណ៍ថា អ្នកគ្រប់គ្រងបានចំណាយលើការទិញស័ង្កសី និងការជួលជាងមកជួសជុល តើជាការចំណាយលើការចាំបាច់ដែរ ឬទេ? ឬអ្នកគ្រប់គ្រងបានទិញសម្ភារៈផ្សេងទៀតដើម្បីបំពាក់លើស័ង្កសីនោះ ដើម្បីការពារការគប់ ឬការពារការទ្រព្យរឹងផ្សេងៗ កុំឲ្យបែកបាក់ ឬធ្លុះធ្លាយជាដើម សួរថានេះជាការចំណាយចាំបាច់ឬទេ? ឬម៉្យាងវិញទៀត អ្នកគ្រប់គ្រង ជួលជាងដែលមានតម្លៃខ្ពស់ជាតម្លៃដែលសាមីខ្លួនធ្លាប់ជួល សួរថា តើនេះជាការចំណាយចាំបាច់ដែរឬទេ? ប្រសិនបើសាមីខ្លួនមិនមានបញ្ហា ឬមិនយកចិត្តទុកដាក់លើការចំណាយនោះទេ នោះវាមិនចាំបាច់ឲ្យអ្នកគ្រប់គ្រងធ្វើការពិចារណានោះទេ ព្រោះថាអ្នកគ្រប់គ្រងអាចនឹងទទួលបានមកវិញ។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើសាមីខ្លួន បានជាមនុស្សដែលមានបញ្ហា ឬគិតគូរយ៉ាងល្អិតល្អន់លើការចំណាយវិញ នោះអ្នកគ្រប់គ្រងចាំបាច់ត្រូវធ្វើការថ្លឹងថ្លែង។ តាមខ្លឹមសារនៃមាត្រានេះ ភាពចាំបាច់នៅទីនេះ គឺភាពថ្លឹងថ្លែងរបស់អ្នកគ្រប់គ្រង ដោយគាត់បានពិចារណាថា អ្វីដែលគួរចំណាយ ឬ មិនគួរចំណាយ ព្រោះវាមានភាពទាក់ទងនឹងការទទួលបានមកវិញនូវការចំណាយលើ ការគ្រប់គ្រងលើទ្រព្យផ្ទាល់ខ្លួន។

**២.២.ការចំណាយសម្រាប់គ្រប់គ្រង និងថែរក្សា ឬចំណាយបង្កើនតម្លៃ**

ក្រៅពីបានពិចារណាទៅលើភាពចាំបាច់នៃការចំណាយហើយនោះ គឺអ្នកគ្រប់គ្រងអាចយកចំណាយចាំបាច់នោះ មកចំណាយតែលើទ្រព្យតែប៉ុណ្ណោះ មិនបានបញ្ញត្តិអំពីការចំណាយចាំបាច់ក្នុងការថែរក្សាបុគ្គលទេ។ មិនមែនឱ្យតែមានការចំណាយលើទ្រព្យនេះ អ្នកគ្រប់គ្រងអាចធ្វើការទាមទារពីសាមីខ្លួនបានទាំងអស់នោះទេ ពោល គឺត្រូវតែមានគោលបំណងនៃការចំណាយច្បាស់លាស់ជាក់ស្តែងនៅក្នុងក្រមរដ្ឋប្បវេណី ត្រង់មាត្រាដដែលនេះ គឺគោលបំណងនៃការចំណាយលើទ្រព្យរួមមាន៖ (១).ការគ្រប់គ្រង និងថែរក្សាទ្រព្យ និង (២).ការបង្កើនតម្លៃតែប៉ុណ្ណោះ។ ប្រសិនអ្នកគ្រប់គ្រងបានធ្វើការចំណាយផ្សេងពីគោលបំណងទាំងពីរនេះ នោះអ្នកគ្រប់គ្រងមិនអាចទាមទារឱ្យសាមីខ្លួន

[30] មាត្រា ៧៣៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

សងសោហ៊ុយវិញទេ។ ឧទាហរណ៍ថា អ្នកគ្រប់គ្រងបានផ្តល់ប្រាក់លើកទឹកចិត្តដល់ជាងជួសជុល បន្ថែមលើថ្លៃឈ្នួល សួរថាតើ ប្រាក់លើកទឹកចិត្តចំណាយក្នុងគោលបំណងអ្វី ហើយសាមីខ្លួនត្រូវមាន ករណីយកិច្ចសងសោហ៊ុយនេះទេ?

**៣.សិទ្ធិទាមទារត្រឹមតែកម្រិតផលប្រយោជន៍ជាក់ស្តែងរបស់សាមីខ្លួន**

ករណីដែលអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានបំពេញនូវសកម្មភាពគ្រប់គ្រងចប់សព្វគ្រប់ ហើយ ប៉ុន្តែការគ្រប់គ្រងនោះធ្វើឡើងដោយផ្ទុយអំពីឆន្ទៈរបស់សាមីខ្លួន ឬមានកំហុសក្នុងអំឡុងពេល នៃការគ្រប់គ្រង នោះអ្នកគ្រប់គ្រងមិនអាចទាមទារឱ្យសាមីខ្លួន សងសោហ៊ុយចំណាយចាំបាច់។ ប៉ុន្តែ អ្នកគ្រប់គ្រងអាចទាមទារសាមីខ្លួន ឲ្យសងបានត្រឹមកម្រិតផលប្រយោជន៍ដែលបានទទួលជាក់ស្តែង តែប៉ុណ្ណោះ។[31]

ឧទាហរណ៍៖ **ក** បានជួសជុលផ្ទះទ្វារផ្ទះឲ្យលោក **ខ** ពេលដែលលោក **ខ** ចាក់ចេញពីផ្ទះ ទៅដើរកម្សាន្តនៅខេត្តកំពត។ មានន័យថា ផលប្រយោជន៍ដែលលោក **ខ** ទទួលបាន គឺរក្សាការពារ យ៉ាងរឹងមាំនៃទ្រព្យសម្បត្តិ និងបង្ការពីហេតុការណ៍ផ្សេងៗ ដូចជា ភ្លៀង ជនឆក់ឱកាស ជាដើម។

**កថាភាគទី២ សិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រង**

ក្នុងករណីដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះ ត្រូវរួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬអាជីវកម្ម របស់អ្នកគ្រប់គ្រងចំពោះកិច្ចការដែលនៅតែធ្វើបន្តនោះ។ ក្រោយពេលដែលសាមីខ្លួនបានដឹងអំពី ការគ្រប់គ្រងដោយឈឺឆ្អាលនោះ រួចហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទាររកកម្រៃដែល ត្រូវបង់ជាទូទៅចំពោះការគ្រប់គ្រងដោយឈឺឆ្អាលនោះបាន។

ចំណុចខាងលើនេះ មានន័យថា បន្ទាប់ពីបានសម្រេចចិត្តក្នុងការជួសជុលជំនួស ម្ចាស់ទ្រព្យ ហើយនោះ បុគ្គលដែលជាអ្នកធ្វើការជួលជុលនោះ មិនត្រឹមតែបានទទួលត្រឡប់មកវិញនូវរាល់ការ ចំណាយបេសសកម្មនោះ។

ផ្អែកតាមក្រមរដ្ឋប្បវេណីប្រទេសជប៉ុន និងប្រទេសថៃ បដិសេធចោលនូវសិទ្ធិទាមទារនូវ កម្រៃពីការគ្រប់គ្រងនោះ ដោយទទួលស្គាល់ចំពោះសោហ៊ុយនៃការគ្រប់គ្រងតែប៉ុណ្ណោះ។ ដោយ ហេតុថា វាហាក់បីដូចជា មានភាពអយុត្តិធម៌ចំពោះសាមីខ្លួនដែលត្រូវអនុវត្តកាតព្វកិច្ចផ្តល់នូវកម្រៃ ប្រសិនបើគាត់ដឹងថា ការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងត្រូវបានដាក់បញ្ចូលទៅក្នុងវិជ្ជាជីវៈ ឬអាជីវកម្ម របស់អ្នកគ្រប់គ្រង។

[31] មាត្រា ៧៣៩ កថាខណ្ឌទី ៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ផ្នែកទី២ ៖ សិទ្ធិរបស់អ្នកត្រូវឲ្យគេគ្រប់គ្រងដោយឈឺឆ្អាល (សាមីខ្លួន)

### ១.សិទ្ធិទាមទារសំណងនៃការខូចមកវិញ

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងដោយឈឺឆ្អាលនោះ គឺដើម្បីតែម្ចាស់ទ្រព្យ ហើយបានធ្វើឲ្យមានការខូចខាតដល់ម្ចាស់សិទ្ធិទ្រព្យនោះ ក្នុងគោលដៅឆ្លៀតឱកាសទុច្ចរិតចង់ក្មេងប្រវ័យផលប្រយោជន៍ ដោយចេតនាដែលឃើញគេកំពុងជួបការលំបាកហើយ រួចទៅថែមបន្ទុកដ៏ធ្ងន់ធ្ងរពេលមានអាសន្ន ឬចេតនាបំផ្លិតបំផ្លាញ ឬមិនប្រុងប្រយ័ត្ន ខ្ជីខ្ជា និងមិនយកចិត្តទុកដាក់ដែលធ្វើឲ្យមានការខូចខាតថែមទៀតបែបនេះ គឺច្បាប់តម្រូវអ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវទទួលខុសត្រូវសងសំណងនៃការខូចខាតមកដល់ខ្លួនបានវិញ (មាត្រា៧៣៣ និងមាត្រា៦៩១ នៃក្រមរដ្ឋប្បវេណី)។

### ២.សិទ្ធិទាមទារឲ្យបញ្ឈប់សកម្មភាពបន្តការគ្រប់គ្រងដោយឈឺឆ្អាល

ជាគោលការណ៍អ្នកគ្រប់គ្រងដោយឈឺឆ្អាល មិនត្រូវបានអនុញ្ញាតឲ្យបញ្ឈប់ការគ្រប់គ្រងដោយការសម្រេចចិត្តរបស់ខ្លួនឯងតែម្ខាងនោះទេ។ ប៉ុន្តែប្រសិនបើច្បាស់លាស់ថា ការគ្រប់គ្រងនោះផ្ទុយនឹងឆន្ទៈរបស់ខ្លួន ឬធ្វើឲ្យខូចផលប្រយោជន៍របស់ខ្លួន ការបន្តការគ្រប់គ្រងមិនអនុញ្ញាត ដោយយោងតាមស្មារតីនៃគោលគំនិតដើមនៃការការគ្រប់គ្រងដោយឈឺឆ្អាលដូចមានចែងក្នុង កថាខណ្ឌទី២ និងទី៣ នៃមាត្រា៧២៩ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះអ្នកគ្រប់គ្រងត្រូវបញ្ឈប់ការគ្រប់គ្រងនោះ ទោះបីជាសាមីខ្លួន ជាអាទិ៍ មិនទាន់បានប្រុងប្រៀបដើម្បីការគ្រប់គ្រងក៏ដោយ។

### ៣.សិទ្ធិទាមទារអោយមានការរាយការណ៍ពីការគ្រប់គ្រង

ក្នុងករណីនេះ សាមីខ្លួនមានសិទ្ធិទាមទារឲ្យអ្នកគ្រប់គ្រងដោយឈឺឆ្អាល រាយការណ៍អំពីស្ថានភាពនៃការគ្រប់គ្រងកិច្ចការ ទោះបីនៅពេលណាក៏ដោយ ក៏ត្រូវរាយការណ៍អំពីហេតុការណ៍ដោយគ្មានការយឺតយ៉ាវ នៅពេលក្រោយពេលបញ្ចប់ការគ្រប់គ្រង។ ក្នុងស្ថានភាពដែលខ្លួនមានការបារម្ភអំពីការគ្រប់គ្រងរបស់អ្នកគ្រប់គ្រង ក៏ដូចជា ខ្លួនមានការបារម្ភថា អ្នកគ្រប់គ្រងបានគ្រប់គ្រងដោយមានចេតនាទុច្ចរិត ឬមានការធ្វេសប្រហែស ឬបណ្តាលឲ្យមានព្យសនកម្មណាមួយបានកើតឡើង ទើបខ្លួនអាចស្នើឲ្យគ្រប់គ្រងធ្វើការរាយការណ៍អំពីហេតុការណ៍នៃការគ្រប់គ្រងឲ្យមកខ្លួនតាមភាពជាក់ស្តែងគ្រប់កាលៈទេសៈតាំងពិចាប់ផ្តើមរហូតដល់ចប់សព្វគ្រប់។

# សេចក្តីសន្និដ្ឋាន

ប្រធានបទ នៃការស្រាវជ្រាវបានឆ្លុះបញ្ចាំងការទំនាក់ទំនងនៃការចេះជួយយកអាសារ និងទុក្ខធុរៈគ្នារបស់ពលរដ្ឋក្នុងសង្គមតាមរយៈការចូលទៅគ្រប់គ្រងដោយឈឺឆ្អាលរបស់បុគ្គលម្នាក់មានចំពោះបុគ្គលម្នាក់ផ្សេងទៀតដែលទទួលបានប្រយោជន៍ពីការគ្រប់គ្រងដោយឈឺឆ្អាលនោះ។ ការចែងបញ្ញត្តិដូចនេះ មិនមែនជាសញ្ញាណមួយថ្មីនាពេលបច្ចុប្បន្ននោះទេ សញ្ញាណនេះមានតាំងពីសម័យអាណានិគមបារាំងមកម្ល៉េះ ជាក់ស្តែងមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ ដែលបញ្ញត្តិនោះចែងតែពីការគ្រប់គ្រងចំពោះតែទ្រព្យសម្បត្តិតែប៉ុណ្ណោះ តែបន្តរហូតមកដល់ពេលនេះ សញ្ញាណគ្រប់ដណ្តប់ទៅលើទាំងទ្រព្យសម្បត្តិ និងចំពោះបុគ្គល បើទោះបីជាមិនបានចែងច្បាស់ពីបុគ្គលក៏ដោយតែពាក្យថាដើម្បីកិច្ចការ និងប្រយោជន៍អ្នកដទៃ(សាមីខ្លួន) គឺរាប់បញ្ចូលទាំងអស់អ្វីជាប្រយោជន៍ និងដើម្បីកិច្ចការអ្នកដទៃ។

ច្បាប់មិនបានបដិសេធចោលចំពោះអំពើនៃការចូលទៅកាន់កាប់ គ្រប់គ្រងទ្រព្យរបស់អ្នកដទៃដោយបំណងសុចរិត ឈឺឆ្អាល និងការពារប្រយោជន៍អ្នកដទៃ បូករួមនឹងលក្ខខណ្ឌ/ធាតុផ្សំនៃអំពើនៃការគ្រប់គ្រងដោយឈឺឆ្អាលបានបំពេញនោះ ថាជាការបំពានទៅលើកម្មសិទ្ធិរបស់បុគ្គលដទៃ។ ដូចនេះ នៅពេលបុគ្គលដទៃចូលទៅគ្រប់គ្រងកិច្ចការ (ដើម្បីជាប្រយោជន៍អ្នកដទៃ) នោះអ្នកគ្រប់គ្រងមានសិទ្ធិទទួលបាននូវសោហ៊ុយ និងកម្រៃពីសាមីខ្លួន។ តែក៏មានការការពារចំពោះម្ចាស់ទ្រព្យផង/សាមីខ្លួន កាលណាការគ្រប់គ្រងធ្វើហួសពីព្រំដែនករណីយកិច្ចគ្រប់គ្រង និង/ឬដោយអំពើទុច្ចរិត។ ទន្ទឹមនឹងនោះ អ្នកគ្រប់គ្រងត្រូវទទួលនូវករណីយកិច្ចគ្រប់គ្រងដើម្បីសាមីខ្លួន ឲ្យបានត្រឹមត្រូវ សុចរិត ស្របតាមឆន្ទៈរបស់ខ្លួន និងបន្តការគ្រប់គ្រងរហូតទាល់តែសាមីខ្ល សន្តតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់។ ប៉ុន្តែ បញ្ញត្តិស្តីពីការគ្រប់គ្រងដោយឈឺឆ្អាលនេះ ធ្វើឲ្យអ្នកសិក្សាមានភាពមិនច្បាស់ ចំពោះពាក្យពេចន៍មួយចំនួនដែលមានចែងក្នុងបញ្ញត្តិទាំងប៉ុណ្ណានោះដូចជាពាក្យ "បុគ្គលដទៃ" ការគ្រប់គ្រងឲ្យស្របតាមឆន្ទៈសាមីខ្លួន និងវិសាលភាពនៃបុគ្គលដែលមានសិទ្ធិទទួលបន្តកិច្ចការគ្រប់គ្រងត្រឹមតែបុគ្គលបីប្រភេទតែប៉ុណ្ណោះ។

គួរបញ្ជាក់ផងដែរថា សញ្ញាណការគ្រប់គ្រងដោយឈឺឆ្អាលមានការប្រែប្រួល កាលណាលក្ខខណ្ឌនៃការជូនដំណឹងទៅដល់សាមីខ្លួន។ មានន័យថា បញ្ញត្តិស្តីពីអាណត្តិ និងការគ្រប់គ្រងដោយឈឺឆ្អាលបានស្ថិតនៅលាយចំរុះគ្នាចំពោះសកម្មភាពរបស់អ្នកគ្រប់គ្រង។

# អនុសាសន៍

ក្រោយពីបានសរសេរ និងរៀបចំនូវសារណាបញ្ចប់ការសិក្សានេះរួចមកសង្កេតឃើញថា ប្រជាពលរដ្ឋមួយចំនួនមិនទាន់មានការយល់ដឹងអំពីអត្ថន័យ នៃការគ្រប់គ្រងដោយឈឺផ្ទាលនៅឡើយ។ ដោយពួកគាត់ភ័យខ្លាចប៉ះពាល់ ឬ បំពានទៅលើសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលដទៃ។ ប៉ុន្តែពួកគាត់មិនបានដឹងពីខ្លឹមសារនៃច្បាប់ដែលតម្រូវឲ្យមនុស្សចេះជួយគ្នាប្រកបដោយសាមគ្គីភាព សុចរិតភាព ស្មោះត្រង់ និងឆ្លើយតបទៅនឹងអំពើប្រកបដោយមនុស្សធម៌ សីលធម៌ និងសមធម៌។ ជាញឹកញាប់បញ្ហាភាគច្រើនកើតឡើងបុគ្គលម្នាក់យករួចខ្លួន ដោយគិតថានៅពេលដែលជួយហើយតែងតែមានទំនាស់នឹងគ្នាដោយមិនទទួលប្រយោជន៍អ្វីពីក្រោយពីការជួយសង្គ្រោះរួចមក។ ពិសេសពិបាកទាមទារសំណងដែលខ្លួនបានចំណាយលើការគ្រប់គ្រងដោយឈឺផ្ទាល។ មួយវិញទៀត នៅពេលដែលមានវិវាទកើតឡើង រវាងអ្នកគ្រប់គ្រង និងសាមីខ្លួន ហើយមិនដឹងថា តើត្រូវប្ដឹងទៅសមត្ថកិច្ចមួយណាទេ។

ដោយសារកង្វះខាតមួយចំនួននេះហើយ ទើបក្រុមយើងខ្ញុំសូមចូលរួមនូវការផ្ដល់ជាយោបល់មួយចំនួនក្នុងគោលដៅដើម្បីធ្វើការកែតម្រូវចំណុចទាំងនោះឲ្យកាន់តែប្រសើរដូចជា៖

- រាជរដ្ឋាភិបាលត្រូវតែផ្ដល់ការផ្សាយជាសារធាណៈច្បាប់ ដើម្បីឲ្យប្រជាពលរដ្ឋបានជ្រួលជ្រាបកាន់តែច្បាស់អំពីខ្លឹមសារនៃការគ្រប់គ្រងដោយឈឺផ្ទាលឲ្យបានទូលំទូលាយ និងផ្ដល់ភាពងាយស្រួលដល់ពួកគាត់ជាសំអាង ហើយក៏ជាចំណេះដឹងបន្ថែមសម្រាប់ពួកគាត់យកទៅប្រើប្រាស់នៅពេលណាដែលពួកគាត់ជួបប្រទះនូវបញ្ហាទាំងនោះ។
- ការចូលរួមចំណែកឈឺផ្ទាលក្នុងសង្គមជាកញ្ចក់ឆ្លុះបញ្ចាំងឲ្យប្រជាពលរដ្ឋចេះជួយគ្នា យកអាសាគ្នា ក្នុងគោលបំណងការពារនូវទ្រព្យសម្បត្តិ ឬបុគ្គល កំពុងជួបទុក្ខលំបាកដែលត្រូវការជំនួយចាំបាច់ដើម្បីជួយឲ្យរួចផុតពីឧបទ្រវហេតុណាមួយ។
- បានបញ្ជាក់ពីសាមគ្គីភាពសង្គមដែលមានប្រជាពលរដ្ឋប្រព្រឹត្តតែអំពើល្អ ចេះជួយទុក្ខធុរៈជនរួមសង្គម និងមានសុវត្ថិភាពក្នុងការរួមរស់នៅជាមួយគ្នា ជាពិសេសបទបញ្ញត្តិស្ដីពីការគ្រប់គ្រងដោយឈឺផ្ទាល បានលើកទឹកចិត្តដល់បុគ្គលគ្រប់រូបដែលបានជួយគ្នាក្នុងគ្រាលំបាកបែបនេះ។

# ឯកសារយោង

I.លិខិតបទដ្ឋានគតិយុត្តិ

១-ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣១ ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី។

២-ក្រមរដ្ឋប្បវេណីសង្គមចាស់ឆ្នាំ១៩២៦

៣-ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

II.ឯកសារផ្សេងៗ

១-មេរៀនរបស់គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គង់ តារាឆាត

២-មេរៀនរបស់គ្រូបង្គោលនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ កេង សុម៉ារិទ្ធិ

៣-សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, បោះពុម្ពលើកទី ០៥, ភ្នំពេញ, ២០១២, ណូមីរ៉ា តូយ៉ូហ៊ីរ៉ូ, ទំព័រ ១០៧,១០៨,១០៩ និង១១០

៤-សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី៣ គន្ថីទី៥, ទំព័រ ១៦៣, ១៦៤, ១៦៥, ១៦៦, ១៦៧, ១៦៨ រៀបចំដោយគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណីឆ្នាំ២០១០។

៥-វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត ,បោះពុម្ពផ្សាយឆ្នាំ ១៩៦៧, ទំព័រ ២៨៥។

III.គេហទំព័រ

- http://books.google.com.kh/books?id=8CkzUuIhALIC&pg=PA194&lpg=PA194&dq=management+of+affair+without+mandate&source=bl&ots=eKRwy3upkz&sig=1PBhJTpmstkgn6yRtpFQBA-ybk0&hl=en&sa=X&ei=xVd_UdCAKq2higf06oGwCw&ved=0CD8Q6AEwAQ#v=onepage&q=management%20of%20affair%20without%20mandate&f=false
- https://web.facebook.com/khmerlaweco/posts/d41d8cd9/964650463698857/?_rdc=1&_rdr
- http://www.thailandlawonline.com/civil-and-commercial-code/395-405-management-of-affairs-without-mandate
- http://leangheng-law.blogspot.com/2013/06/blog-post.html

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

## រចនាសម្ព័ន្ធនៃកាតព្វកិច្ច




https://web.facebook.com/588125011345987/photos/d41d8cd9/1168771769947972/?_rdc=1&_rdr




http://knowledgeoncambodialaws.blogspot.com/2017/02/

# ឧបសម្ព័ន្ធ២

## ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

## ជំពូកទី ១៤
## ការគ្រប់គ្រងដោយឈឺឆ្អាល

**មាត្រា ៧២៩.–** ករណីយកិច្ចគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ ការចាប់ផ្ដើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល ។ បុគ្គលដែលធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល ។

២-អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវគ្រប់គ្រងដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាងគេ ដើម្បីផលប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការនោះ ។

៣-ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានដឹងអំពីឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើអាចដឹងអំពីឆន្ទៈនោះបាន ត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ ។

**មាត្រា ៧៣០.–** ការគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ដើម្បីជៀសវាងគ្រោះថ្នាក់ នៅក្នុងសភាពបន្ទាន់ ចំពោះរូបកាយសាមីខ្លួន កិត្តិយស ឬ ទ្រព្យសម្បត្តិ លុះត្រាតែគ្មានគំនិតទុច្ចរិត ឬ កំហុសធ្ងន់ធ្ងរ តែប៉ុណ្ណោះទេ ទើបអ្នកគ្រប់គ្រងដោយឈឺឆ្អាល ពុំមានការទទួលខុសត្រូវលើសំណងនៃការខូចខាត ដែលកើតឡើងដោយសារការគ្រប់គ្រងនោះ ។

**មាត្រា ៧៣១.–** ករណីយកិច្ចជូនដំណឹងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវជូនដំណឹងអំពីការបានចាប់ផ្ដើមការគ្រប់គ្រងដោយឈឺឆ្អាលទៅឱ្យសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ ក្នុងករណីដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនោះហើយ ការជូនដំណឹងនេះពុំចាំបាច់ឡើយ ។

**មាត្រា ៧៣២.–** ករណីយកិច្ចបន្តការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបន្តការគ្រប់គ្រងនោះ រហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់សាមីខ្លួននោះ អាចធ្វើការគ្រប់គ្រងបាន ។ ប៉ុន្តែ ប្រសិនបើការបន្តការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើច្បាស់ថានឹងធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួន ត្រូវបញ្ឈប់ការគ្រប់គ្រងនោះ ។

**មាត្រា ៧៣៣.–** ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤១ (ករណីយកិច្ចរាយការណ៍ របស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៣ (ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ នៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាល ។

**មាត្រា ៧៣៤.–** សិទ្ធិទាមទារសងសោហ៊ុយវិញរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ប្រសិនបើបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ឬ ចំណាយបង្កើនតម្លៃ ដើម្បីសាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទារ ចំពោះសាមីខ្លួនឱ្យសងវិញបាន ។

២-បញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានទទួលបន្ទុកកាតព្វកិច្ចដែលជាសោហ៊ុយដែលបានបង្កើនតម្លៃ ដើម្បីសាមីខ្លួន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្ត ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលសាមីខ្លួនបានទទួលជាក់ស្តែង ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងផ្ទុយពីឆន្ទៈរបស់សាមីខ្លួន ។

**មាត្រា ៧៣៥.–** សិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

ក្នុងករណីដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះរួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬ អាជីវ-

កម្មរបស់អ្នកគ្រប់គ្រង ចំពោះកិច្ចការដែលនៅតែធ្វើបន្ត ក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះរួចហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារកម្រៃដែលត្រូវបង់ជាទូទៅ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាលនោះបាន ។

# ឧបសម្ព័ន្ធទី៣

## សេចក្តីកំណត់ពន្យល់មាត្រានីមួយៗ

## នៃក្រមរដ្ឋប្បវេណី

## ជំពូកទី ១៤ ការគ្រប់គ្រងដោយឈឺឆ្អាល

**មាត្រា ៧២៩.-** ករណីយកិច្ចគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ ការចាប់ផ្តើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ហៅថា ការគ្រប់គ្រងដោយឈឺឆ្អាល ។ បុគ្គលដែលធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល ។

២-អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវគ្រប់គ្រងដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាងគេ ដើម្បីផលប្រយោជន៍របស់សាមីខ្លួន ផ្អែកតាមលក្ខណៈនៃកិច្ចការនោះ ។

៣-ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានដឹងអំពីឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើអាចដឹងអំពីឆន្ទៈនោះបាន ត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ ។

(កំណត់)

(1) ក្នុងជីវភាពប្រចាំថ្ងៃ មនុស្សយើងជានិច្ចកាលយកចិត្តទុកដាក់ចំពោះកិច្ចការរបស់អ្នកដទៃ ទោះបីជាគ្មានសិទ្ធិអំណាច ឬ ករណីយកិច្ចតាមផ្លូវច្បាប់ដើម្បីធ្វើបែបនោះក៏ដោយ ។ ដូចដែលយើងដឹងស្រាប់ហើយថា ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង សាមគ្គីភាពសង្គម និង កិច្ចសហប្រតិបត្តិការទៅវិញទៅមក មានសារៈសំខាន់ណាស់នៅក្នុងជីវិតរបស់មនុស្សយើង ។ ប៉ុន្តែ វាច្បាស់ណាស់ទៅហើយដែលថា ការជួយគ្នាទៅវិញទៅមកនេះ គឺជា "ការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃ" ។ ប្រសិនបើយើងអនុវត្តគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនឱ្យដាក់លាក់ទៅ ការជួយគ្នាទៅវិញទៅមកបែបនេះ ត្រូវបានវាយតម្លៃថា ខុសច្បាប់ ។ ដោយសារតែហេតុផលនេះហើយ ជាករណីលើកលែងចំពោះគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន ជំពូកនេះដាក់បញ្ចូលនូវបញ្ញត្តិដែលធ្វើឱ្យ "ការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃ" មិនខុសច្បាប់ ប្រសិនបើការជ្រៀតជ្រែកនោះបានបំពេញនូវល័ក្ខខ័ណ្ឌមួយចំនួន និង បញ្ញត្តិដទៃផ្សេងទៀតដែលពាក់ព័ន្ធជាមួយនឹងទំនាក់ទំនងសិទ្ធិ និង ករណីយកិច្ចរវាងអ្នកគ្រប់គ្រងដោយឈឺឆ្អាល និង សាមីខ្លួន ។ ដោយសារទំនាក់ទំនងនេះកើតឡើងដោយច្បាប់ តែមិនមែនដោយឆន្ទៈរបស់ភាគី ទំនាក់ទំនងនេះត្រូវបានហៅថាជា "ទំនាក់ទំនងនៃកាតព្វកិច្ចដែលកំណត់ដោយច្បាប់" ។

(2) កថាខណ្ឌទី ១ នៃមាត្រានេះកំណត់និយមន័យថា "ការជ្រៀតជ្រែកចូលក្នុងកិច្ចការអ្នកដទៃ" តាមរយៈការជួយគ្នាទៅវិញទៅមក គឺជា "ការគ្រប់គ្រងដោយឈឺឆ្អាល" ហើយឱ្យនិយមន័យថា បុគ្គលដែលប្រតិបត្តិការគ្រប់គ្រង គឺជាអ្នកគ្រប់គ្រងដោយឈឺឆ្អាល ។

ដើម្បីឱ្យសកម្មភាពមួយអាចត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាល អ្នកគ្រប់គ្រងចាំបាច់ត្រូវមានឆន្ទៈ

គ្រប់គ្រងកិច្ចការ "ដើម្បីបុគ្គលដទៃ" ។ ឆន្ទៈនេះគឺហៅថា "ឆន្ទៈគ្រប់គ្រង" ។ ប្រសិនបើអ្នកគ្រប់គ្រងគ្មានឆន្ទៈគ្រប់គ្រងទេ សកម្មភាពគ្រប់គ្រងនោះមិនត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលទេ ហើយអ្នកគ្រប់គ្រងមិនអាចទាមទារឱ្យសងវិញនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងនោះ ជាអាទិ៍ ទេ ។ ប៉ុន្តែ សកម្មភាពមួយក៏អាចត្រូវបានចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាលផងដែរ ប្រសិនបើអ្នកគ្រប់គ្រងមានទាំងឆន្ទៈគ្រប់គ្រង "ដើម្បីបុគ្គលដទៃ" និង "ដើម្បីសាមីខ្លួន" ។ ឧទាហរណ៍ ដូចជា ប្រសិនបើច្រាំងទន្លេទំនងជាត្រូវបាក់ដោយសារការកើនឡើងនៃទឹកទន្លេ ហើយមានអ្នករស់នៅក្បែរដងទន្លេណាម្នាក់ ចាត់វិធានការជាបន្ទាន់ ដើម្បីទប់កុំឱ្យច្រាំងបាក់ ដើម្បីការពារមិនមែនតែផ្ទះខ្លួនឯងប៉ុណ្ណោះទេ គឺដើម្បីការពារផ្ទះអ្នកជិតខាងដែរ សកម្មភាពបែបនោះនឹងត្រូវចាត់ទុកថាជាការគ្រប់គ្រងដោយឈឺឆ្អាល ។

ពាក្យថា "ការគ្រប់គ្រង" ដែលប្រើនៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាល គឺខុសគ្នាពីគោលគំនិតនៃ "ការគ្រប់គ្រង" ដែលត្រូវបានប្រើនៅក្នុងផ្នែកដទៃទៀតនៃក្រមរដ្ឋប្បវេណី ត្រង់ចំណុចថា ពាក្យ "គ្រប់គ្រង" ដែលត្រូវបានប្រើក្នុងការគ្រប់គ្រងដោយឈឺឆ្អាលនោះ រាប់បញ្ចូលទាំងសកម្មភាពចាត់ចែងផងដែរ ។ ប៉ុន្តែ ការចាត់ចែងនេះត្រូវតែធ្វើឡើងតាមមធ្យោបាយសមស្របបំផុតដើម្បីផលប្រយោជន៍របស់សាមីខ្លួន ។

(3) កថាខណ្ឌទី ២ ចែងអំពីករណីយកិច្ចជាមូលដ្ឋានរបស់អ្នកគ្រប់គ្រងថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល មានករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត ដើម្បីគ្រប់គ្រងកិច្ចការតាមវិធីដែលសមរម្យជាងគេដើម្បីផលប្រយោជន៍របស់សាមីខ្លួន ។ ប្រសិនបើអ្នកគ្រប់គ្រងមិនបានបំពេញករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិតទេ សកម្មភាពគ្រប់គ្រងនោះត្រូវចាត់ទុកថា ខុសច្បាប់ ហើយអ្នកគ្រប់គ្រងត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាតដែលកើតឡើងពីការខកខាននោះ ។

ករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត មានន័យថា ជាការគ្រប់គ្រងកិច្ចការដោយមានការយកចិត្តទុកដាក់ខ្ពស់ ដែលអ្នកប្រកបដោយវិចារណញ្ញាណនឹងធ្វើ ក្នុងស្ថានភាពជាក់លាក់ណាមួយ ។

(4) ចំពោះបញ្ហាថា តើសកម្មភាពរបស់អ្នកគ្រប់គ្រងបម្រើ ឬ មិនបម្រើឱ្យផលប្រយោជន៍របស់សាមីខ្លួន ជាគោលការណ៍ត្រូវវិនិច្ឆ័យដោយសាមីខ្លួនផ្ទាល់ ។ ហេតុដូច្នេះ ក្នុងករណីដែលអ្នកគ្រប់គ្រងបានដឹង ឬ អាចដឹងបាននូវឆន្ទៈរបស់សាមីខ្លួន អ្នកគ្រប់គ្រងត្រូវគ្រប់គ្រងកិច្ចការដោយយោងតាមឆន្ទៈរបស់សាមីខ្លួននោះ ។ កថាខណ្ឌទី ៣ បញ្ជាក់អំពីចំណុចនេះ ។ ក្នុងករណីដែលអ្នកគ្រប់គ្រងមិនអាចដឹងឆន្ទៈរបស់សាមីខ្លួនទេ ឆន្ទៈរបស់សាមីខ្លួននោះ ត្រូវបានវិនិច្ឆ័យដោយយោងតាមទស្សនៈទូទៅក្នុងសង្គម ដោយគិតពិចារណានូវលក្ខណៈនៃកិច្ចការ កាលៈទេសៈជាក់ស្តែងជុំវិញសកម្មភាពគ្រប់គ្រង ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៧ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៧៧ មាត្រា ៦៧៩ និង មាត្រា ៦៨៧៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ៤១៩ នៃច្បាប់ស្តីពីកាតព្វកិច្ចនៃប្រទេសស្វីស, មាត្រា ៨២៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា

**មាត្រា ៧៣០.-** ការគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់

ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ដើម្បីជៀសវាងគ្រោះថ្នាក់ នៅក្នុងសភាពបន្ទាន់ ចំពោះរូបកាយសាមីខ្លួន កិត្តិយស ឬ ទ្រព្យសម្បត្តិ លុះត្រាតែគ្មានគំនិតទុច្ចរិត ឬ កំហុសធ្ងន់ធ្ងរ តែប៉ុណ្ណោះទេ ទើបអ្នកគ្រប់គ្រងដោយឈឺឆ្អាល ពុំមានការទទួលខុសត្រូវលើសំណងនៃការខូចខាត ដែលកើតឡើងដោយសារការគ្រប់គ្រងនោះ ។

(កំណត់)

ប្រសិនបើផលប្រយោជន៍តាមផ្លូវច្បាប់របស់អ្នកដទៃ ដែលមានដូចជា ជីវិត ឬ ទ្រព្យសម្បត្តិ ជាដើម ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ សកម្មភាពដើម្បីសង្គ្រោះផលប្រយោជន៍ស្របច្បាប់ទាំងអស់នោះ មិនមែនគ្រាន់តែគួរតែទទួលស្គាល់ថា ស្របច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែ គួរតែត្រូវបានគាំទ្រយ៉ាងសកម្មផងដែរ ពីទស្សនៈនៃការជួយគ្នាទៅវិញទៅមក ។ ហេតុដូច្នេះ ចំពោះសកម្មភាពគ្រប់គ្រងក្នុងករណីដែលមានស្ថានភាពបន្ទាន់ មាត្រានេះបន្ថយនូវករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកគ្រប់គ្រងតិចជាងការគ្រប់គ្រងដោយឈឺឆ្អាលក្នុងករណីធម្មតា ហើយចែងថា អ្នកគ្រប់គ្រងមិនមានការទទួលខុសត្រូវក្នុងការសងសំណងការខូតខាតទៅសាមីខ្លួនឡើយ ចំពោះរាល់ការខូតខាតទាំងឡាយណាដែលបង្កឡើងដោយសកម្មភាពគ្រប់គ្រងដោយឈឺឆ្អាលក្នុងភាពបន្ទាន់ លើកលែងតែអ្នកគ្រប់គ្រងនោះមានគំនិតទុច្ចរិត ឬ កំហុសធ្ងន់ធ្ងរ ។ម្យ៉ាងទៀត ស្ថានភាពបន្ទាន់ក៏ត្រូវគិតពិចារណាដាក់ចូលជាកត្តាសម្រាប់កាត់បន្ថយនូវករណីយកិច្ចប្រុងប្រយ័ត្នរបស់អ្នកគ្រប់គ្រងដែរ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៨ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨០ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៣៧៤ នៃក្រមរដ្ឋប្បវេណីបារាំង, កថាខណ្ឌទី ២ មាត្រា ៤២០ នៃច្បាប់ស្តីពីកាតព្វកិច្ចនៃប្រទេសស្វីស

**មាត្រា ៧៣១.-** ករណីយកិច្ចជូនដំណឹងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវជូនដំណឹងអំពីការបានចាប់ផ្តើមការគ្រប់គ្រងដោយឈឺឆ្អាលទៅឱ្យសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ ក្នុងករណីដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងនោះហើយ ការជូនដំណឹងនេះពុំចាំបាច់ឡើយ ។

(កំណត់)

(1) ជាទូទៅ នៅពេលណាដែលការគ្រប់គ្រងដោយឈឺឆ្អាលចាប់ផ្តើម សាមីខ្លួនច្រើនតែមិនដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះទេ ។ ទោះបីជាការគ្រប់គ្រងដោយឈឺឆ្អាលនេះ គឺជាការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាងក៏ដោយ

ក៏វានៅតែជាការជ្រៀតជ្រែកចូលទៅក្នុងកិច្ចការរបស់អ្នកដទៃដែរ ហេតុដូច្នេះ តាមគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន គួរតែសាមីខ្លួនចូលរួមនៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាលនោះឱ្យបានឆាប់តាំងពីដំបូងតាមដែលអាចធ្វើទៅបាន ។ ដោយសារមូលហេតុនេះ មាត្រានេះកំណត់អំពីករណីយកិច្ចរបស់អ្នកគ្រប់គ្រង ក្នុងការជូនដំណឹងអំពីការចាប់ផ្តើមការគ្រប់គ្រងនោះ ទៅសាមីខ្លួន ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ ប្រសិនបើមិនស្គាល់សាមីខ្លួនទេ អ្នកគ្រប់គ្រងមិនចាំបាច់ធ្វើការជូនដំណឹងទេ ដោយសារតែអ្នកគ្រប់គ្រងមិនអាចធ្វើការជូនដំណឹងទៅសាមីខ្លួនបានឡើយ ។

(2) ភាពយឺតយ៉ាវ ឬ មិនយឺតយ៉ាវនៃការជូនដំណឹង ត្រូវវិនិច្ឆ័យទៅតាមលក្ខណៈនៃការគ្រប់គ្រងកិច្ចការនោះ ។ ប្រសិនបើកិច្ចការដែលត្រូវបានគ្រប់គ្រងនោះ គឺជាកិច្ចការតែមួយដង អ្នកគ្រប់គ្រងហាក់ដូចជាមិនចាំបាច់ធ្វើការជូនដំណឹងទេ ។ ប៉ុន្តែ ដោយសារបញ្ញត្តិស្តីពីអាណត្តិត្រូវយកមកអនុវត្តដូចគ្នាផងដែរ អ្នកគ្រប់គ្រងមានករណីយកិច្ចរាយការណ៍នៅចុងបញ្ចប់ អ្នកគ្រប់គ្រងត្រូវតែជូនដំណឹង (រាយការណ៍) ទៅសាមីខ្លួន ទោះបីជាកិច្ចការគ្រប់គ្រងជាកិច្ចការតែមួយដងក៏ដោយ ។

(3) ដោយសារការជូនដំណឹងដែលបានចែងនៅក្នុងមាត្រានេះ មានគោលបំណងបញ្ជាក់ថា តើសាមីខ្លួនយល់ព្រម ឬ មិនយល់ព្រមចំពោះ ការគ្រប់គ្រងកិច្ចការ អ្នកគ្រប់គ្រងត្រូវរង់ចាំការចង្អុលបង្ហាញពីសាមីខ្លួន លើកលែងតែក្នុងស្ថានភាពពិសេស ដែលការរង់ចាំនឹងបង្កនូវការខូចខាតដល់ផលប្រយោជន៍របស់សាមីខ្លួន ។ ប៉ុន្តែ រហូតទាល់តែមានការចង្អុលបង្ហាញពីសាមីខ្លួនទៅចំពោះអ្នកគ្រប់គ្រង អ្នកគ្រប់គ្រងនៅតែបន្តការគ្រប់គ្រងដែលស្របទៅនឹងឆន្ទៈដែលអាចយល់បានរបស់សាមីខ្លួន ឬ ប្រសិនបើមិនអាចប្រមាណយល់បានអំពីឆន្ទៈរបស់សាមីខ្លួនទេ អ្នកគ្រប់គ្រងត្រូវបន្តការគ្រប់គ្រងឱ្យបានស្របនឹងផលប្រយោជន៍របស់សាមីខ្លួន ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៦៩៩ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧៣២.-** ករណីយកិច្ចបន្តការគ្រប់គ្រងរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបន្តការគ្រប់គ្រងនោះ រហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់សាមីខ្លួននោះ អាចធ្វើការគ្រប់គ្រងបាន ។ ប៉ុន្តែ ប្រសិនបើការបន្តការគ្រប់គ្រងនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ប្រសិនបើច្បាស់ថានឹងធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួន ត្រូវបញ្ឈប់ការគ្រប់គ្រងនោះ ។

(កំណត់)

(1) មាត្រានេះកំណត់ថា អ្នកគ្រប់គ្រងដែលបានចាប់ផ្តើមការគ្រប់គ្រង ត្រូវបន្តការគ្រប់គ្រងនោះរហូតដល់ពេលណាមួយ ។ ប្រសិនបើកិច្ចការដែលត្រូវបានគ្រប់គ្រងនោះ ជាកិច្ចការដែលត្រូវធ្វើតែមួយដង នោះនឹងមិនមានបញ្ហាអ្វីកើតឡើងទេ

ដោយសារការគ្រប់គ្រងនោះ ត្រូវចប់នៅពេលដែលអ្នកគ្រប់គ្រងបំពេញកិច្ចការគ្រប់គ្រងចប់សព្វគ្រប់ ។ ប៉ុន្តែ ប្រសិនបើកិច្ចការទាមទារឱ្យមានការគ្រប់គ្រងជាបន្ត ហើយអំឡុងពេលដែលត្រូវធ្វើការគ្រប់គ្រងនោះ មិនបានកំណត់ជាក់លាក់ទេនោះ បញ្ហានឹងកើតឡើងថា តើអ្នកគ្រប់គ្រងត្រូវបន្តគ្រប់គ្រងរហូតដល់ពេលណា ។ ដើម្បីដោះស្រាយបញ្ហានេះ មាត្រានេះចែងថា អ្នកគ្រប់គ្រងត្រូវបន្តការគ្រប់គ្រងរហូតដល់មានហេតុជាក់លាក់ណាមួយកើតឡើង ។

(2) អ្នកគ្រប់គ្រងមានករណីយកិច្ចបន្តធ្វើការគ្រប់គ្រងរហូតដល់ពេលដែលសាមីខ្លួន សន្តតិជន ឬ អ្នកតំណាងដែលច្បាប់បានកំណត់ អាចប្រុងប្រៀបដើម្បីធ្វើការគ្រប់គ្រងដោយខ្លួនឯងបាន ។ ប្រសិនបើអ្នកគ្រប់គ្រងចាប់ផ្តើមធ្វើការគ្រប់គ្រងដោយឈឺឆ្អាល ហើយបោះបង់ចោលពាក់កណ្តាលទី អំពើរបៀបនេះនឹងបង្កឱ្យមានការខូចខាតមិនត្រឹមត្រូវដល់សាមីខ្លួនជាញឹកញាប់ ។ ដោយសារតែហេតុផលនេះហើយ ជាគោលការណ៍ អ្នកគ្រប់គ្រងមិនត្រូវបានអនុញ្ញាតឱ្យបញ្ឈប់ការគ្រប់គ្រងដោយការសម្រេចចិត្តរបស់ខ្លួនឯងតែម្ខាងនោះទេ ។ ប៉ុន្តែ ប្រសិនបើមានភាពច្បាស់លាស់ថា ការគ្រប់គ្រងដោយឈឺឆ្អាលនោះ ផ្ទុយនឹងឆន្ទៈរបស់សាមីខ្លួន ឬ ធ្វើឱ្យខូចផលប្រយោជន៍របស់សាមីខ្លួន ការបន្តការគ្រប់គ្រងមិនត្រូវបានអនុញ្ញាត ដោយយោងតាមស្មារតីនៃគោលគំនិតដើមនៃការគ្រប់គ្រងដោយឈឺឆ្អាលដូចមានចែងក្នុង កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ នៃមាត្រា ៧២៩ ហេតុដូច្នេះ អ្នកគ្រប់គ្រងត្រូវបញ្ឈប់ការគ្រប់គ្រង ទោះបីជាសាមីខ្លួន ជាអាទិ៍ មិនទាន់បានប្រុងប្រៀបដើម្បីធ្វើការគ្រប់គ្រងក៏ដោយ ។ វាក្យខណ្ឌទី ២ នៃមាត្រានេះ ធ្វើការបញ្ជាក់ឱ្យច្បាស់ឡើងវិញនូវគោលគំនិតនេះ ។

(3) មាត្រានេះមិនមានបញ្ញត្តិចែងថា តើការគ្រប់គ្រងដោយឈឺឆ្អាលត្រូវបញ្ចប់ដែរ ឬ យ៉ាងណានោះទេ នៅពេលដែលអ្នកគ្រប់គ្រងទទួលមរណភាព ។ ទោះបីជាមានលទ្ធភាពក្នុងការបកស្រាយថា សន្តតិជនរបស់អ្នកគ្រប់គ្រង ត្រូវទទួលសន្តតិកម្មនូវករណីយកិច្ចបន្តគ្រប់គ្រងកិច្ចការក៏ដោយ ក៏សន្តតិជននោះអាចនឹងមិនមានសមត្ថភាពគ្រប់គ្រងបានត្រឹមត្រូវដែរ ឧទាហរណ៍ដូចជាករណីដែលសន្តតិជនរស់នៅឆ្ងាយ ជាដើម ។ ដោយសារតែសុឆន្ទៈរបស់អ្នកគ្រប់គ្រង មានសារៈសំខាន់ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាល ហើយដោយសារតែមរណភាពរបស់អាណត្តិគាហក ក៏ជាមូលហេតុមួយនៃការបញ្ចប់អាណត្តិ (មាត្រា ៦៤៩) វាប្រហែលជាសមរម្យក្នុងការបកស្រាយថា ការគ្រប់គ្រងដោយឈឺឆ្អាលត្រូវបញ្ចប់នៅពេលដែលអ្នកគ្រប់គ្រងទទួលមរណភាព ។ ប៉ុន្តែ បញ្ហានេះទុកឱ្យតុលាការសម្រេចថា តើត្រូវប្រកាន់យកការបកស្រាយមួយណានោះ ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០០ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ២ មាត្រា ១៣៧២ នៃ ក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៧៣៣.-** ការយកបញ្ញត្តិនៃអាណត្តិមកអនុវត្តដូចគ្នា

បញ្ញត្តិចាប់ពីមាត្រា ៦៤១ (ករណីយកិច្ចរាយការណ៍ របស់អាណត្តិគាហក) រហូតដល់មាត្រា ៦៤៣ (ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ នៅក្នុងការគ្រប់គ្រងដោយឈឺឆ្អាល ។

(កំណត់)

ទោះបីជាការគ្រប់គ្រងដោយឈឺឆ្អាលមិនត្រូវបានធ្វើឡើងដោយផ្អែកលើឆន្ទៈរបស់សាមីខ្លួនក៏ដោយ ក៏វាស្រដៀងគ្នានឹងកិច្ចសន្យាអាណត្តិដែរ ត្រង់ចំណុចថា តាមរយៈកិច្ចសន្យាអាណត្តិ អាណត្តិគាហកធ្វើការចាត់ចែងកិច្ចការរបស់អាណត្តិទាយក ឯតាមការគ្រប់គ្រងដោយឈឺឆ្អាល អ្នកគ្រប់គ្រងធ្វើការចាត់ចែងកិច្ចការដោយឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីផលប្រយោជន៍របស់សាមីខ្លួន ។ ដូច្នេះ វាទំនងជាសមរម្យដែលអ្នកគ្រប់គ្រងត្រូវទទួលបន្ទុកនូវករណីយកិច្ច ដូចគ្នានឹងករណីយកិច្ចដែលអាណត្តិគាហកត្រូវទទួលបន្ទុក ។ ហេតុដូច្នេះ មាត្រានេះចែងថា បញ្ញត្តិចាប់ពីមាត្រា ៦៤១ (ករណីយកិច្ចរាយការណ៍របស់អាណត្តិគាហក) ដល់មាត្រា ៦៤៣ (ករណីយកិច្ចសងសំណងនៃការខូចខាតរបស់អាណត្តិគាហកដែលបានប្រើប្រាក់) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាល ។

(មាត្រាពាក់ព័ន្ធ)

មាត្រា ៧០១ នៃក្រមរដ្ឋប្បវេណីជប៉ុន, កថាខណ្ឌទី ២ មាត្រា ១៣៧២ នៃក្រមរដ្ឋប្បវេណីបារាំង, មាត្រា ៦៨១ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់

**មាត្រា ៧៣៤.-** សិទ្ធិទាមទារសងសោហ៊ុយវិញរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

១-ប្រសិនបើបានចេញចំណាយជាចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ឬចំណាយបង្កើនតម្លៃ ដើម្បីសាមីខ្លួន អ្នកគ្រប់គ្រងដោយឈឺឆ្អាលអាចទាមទារ ចំពោះសាមីខ្លួនឱ្យសងវិញបាន ។

២-បញ្ញត្តិកថាខណ្ឌទី ២ នៃមាត្រា ៦៤៦ (សិទ្ធិទាមទារឱ្យសងមកវិញ ជាអាទិ៍ នូវសោហ៊ុយរបស់អាណត្តិគាហក) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានទទួលបន្ទុកកាតព្វកិច្ចដែលជាសោហ៊ុយដែលបានបង្កើនតម្លៃ ដើម្បីសាមីខ្លួន ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវយកមកអនុវត្ត ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលសាមីខ្លួនបានទទួលជាក់ស្តែង ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានធ្វើការគ្រប់គ្រងផ្ទុយពីឆន្ទៈរបស់សាមីខ្លួន ។

(កំណត់)

(1) អត្ថប្រយោជន៍ក្នុងការទទួលស្គាល់ការបង្កើតសកម្មភាពគ្រប់គ្រងដោយឈឺឆ្អាល មាននៅត្រង់ចំណុចថា ប្រសិនបើសកម្មភាពគ្រប់គ្រងមួយរបស់អ្នកគ្រប់គ្រងត្រូវបានចាត់ទុកថាជាស្របច្បាប់ ករណីយកិច្ចមួយចំនួននឹងកើតឡើងចំពោះសាមីខ្លួន ដោយសារតែសកម្មភាពស្របច្បាប់របស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល ។ ក្នុងចំណោមករណីយកិច្ចដែលកើតឡើងចំពោះសាមីខ្លួន ករណីយកិច្ចមួយដែលទទួលស្គាល់បានដោយមិនមានមន្ទិល គឺករណីយកិច្ចសងនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រង ។ បើនិយាយពីទស្សនៈនៃអ្នកគ្រប់គ្រងវិញ វាគឺជាសិទ្ធិទាមទារឱ្យសងនូវសោហ៊ុយ ។

ដោយសារតែការគ្រប់គ្រងដោយឈឺឆ្អាលបម្រើឱ្យផលប្រយោជន៍របស់សាមីខ្លួន យ៉ាងហោចណាស់ សាមីខ្លួនត្រូវទទួលបន្ទុកនូវសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងដែរ ។ វាសមហេតុសមផលដែលយើងគិតបែបដូច្នេះថា "ទីណាមានផលប្រយោជន៍ ទីនោះមានបន្ទុកនូវសោហ៊ុយ" ។ កថាខណ្ឌទី ១ កំណត់ច្បាស់លាស់អំពីបញ្ហានេះ ។

(2) ប្រសិនបើអ្នកគ្រប់គ្រងទទួលបន្ទុកនូវកាតព្វកិច្ច ក្នុងការប្រតិបត្តិនូវការគ្រប់គ្រងដោយឈឺឆ្អាល វាមានលក្ខណៈងាយស្រួលដែលអ្នកគ្រប់គ្រងអាចមិនត្រឹមតែអនុវត្តកាតព្វកិច្ច និង ទាមទារឱ្យសាមីខ្លួនសងសោហ៊ុយមកវិញ ដោយយោងតាមកថាខណ្ឌទី ១ ប៉ុន្តែ អាចទាមទារឱ្យសាមីខ្លួនអនុវត្តកាតព្វកិច្ចជំនួសអ្នកគ្រប់គ្រងដោយឈឺឆ្អាលដែរនោះ ។ ការអនុវត្តរបៀបនេះនឹងកាត់បន្ថយនូវហានិភ័យរបស់អ្នកគ្រប់គ្រងផងដែរ ។ ដោយគិតដល់បញ្ហានេះហើយ ទើបយើងបង្កើតឱ្យមានកថាខណ្ឌទី ២ ឡើង ។

(3) វាទាមទារឱ្យមានការគិតពិចារណាបន្ថែមដើម្បីកំណត់ថា ការខូចខាតដែលអ្នកគ្រប់គ្រងទទួលរង នៅពេលប្រតិបត្តិការគ្រប់គ្រងដោយឈឺឆ្អាល គួរត្រូវបានដាក់បញ្ចូលនៅក្នុងសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងដែរ ឬទេ ។ ដូចកថាខណ្ឌទី ៣ នៃមាត្រា ៦៤៦ ដែលពាក់ព័ន្ធនឹងអាណត្តិដែរ វាអាចត្រូវបានបកស្រាយថា អ្នកគ្រប់គ្រងអាចទាមទារនូវសំណងការខូចខាតពីសាមីខ្លួន ចំពោះការខូចខាតទាំងឡាយណាដែលអ្នកគ្រប់គ្រងទទួលរងដោយគ្មានកំហុស ។ ប៉ុន្តែ យើងក៏អាចគិតបានដែរថា អ្នកគ្រប់គ្រងដោយឈឺឆ្អាលមិនមានសិទ្ធិទាមទារសំណងការខូចខាតពីសាមីខ្លួនទេ ពីព្រោះអ្នកគ្រប់គ្រងដោយឈឺឆ្អាល ដែលធ្វើកិច្ចការ មិនមែនដោយផ្អែកលើឆន្ទៈរបស់សាមីខ្លួន មិនគួរត្រូវបានចាត់ចែងដូចគ្នានឹងអាណត្តិគាហកដែលធ្វើកិច្ចការ ដោយផ្អែកលើកិច្ចសន្យាអាណត្តិដែលធ្វើជាមួយសាមីខ្លួន (អាណត្តិទាយក) នោះទេ ។

ជាទូទៅ ដោយសារតែមានករណីច្រើនប្រភេទដែលអ្នកគ្រប់គ្រងដោយឈឺឆ្អាលទទួលរងនូវការខូចខាត នៅពេលអនុវត្តការគ្រប់គ្រងដោយឈឺឆ្អាល វាហាក់ដូចជាមានភាពសមរម្យដែលថា ការសម្រេចថា តើការខូចខាតត្រូវដាក់បញ្ចូល

ទៅក្នុងសោហ៊ុយដែលបានចំណាយសម្រាប់ការគ្រប់គ្រងដែរ ឬយ៉ាងណានោះ ត្រូវទុកឱ្យតុលាការវិនិច្ឆ័យ ដោយផ្អែកទៅតាមស្ថានភាពជាក់លាក់នីមួយៗ ។ ប្រសិនបើបុគ្គលណាម្នាក់បានជួយអ្នកដែលលង់ទឹក ហើយសម្លៀកបំពាក់របស់ខ្លួនប្រឡាក់កខ្វក់ ការខូចខាតនោះត្រូវបានបង្កឡើងជាធម្មតា នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងដោយឈឺឆ្អាល ហេតុដូច្នេះ ការខូចខាតនោះត្រូវរាប់បញ្ចូលទៅក្នុងសោហ៊ុយ ។ ប៉ុន្តែ ប្រសិនបើបុគ្គលនោះ ទៅប៉ះទង្គិចជាមួយនឹងឈើអណ្តែតទឹក ហើយមានរបួស ការខូចខាតនោះបានកើតឡើងដោយគ្រោះថ្នាក់ចៃដន្យនាអំឡុងពេលជួយសង្គ្រោះ ហេតុដូច្នេះ វានៅមានការជជែកដេញដោលគ្នាថា តើរបួសស្នាមដោយគ្រោះថ្នាក់ចៃដន្យនាអំឡុងពេលជួយសង្គ្រោះនោះ គួរដាក់បញ្ចូលក្នុងសោហ៊ុយដែរ ឬទេ ។ យើងអាចនិយាយបានថា បញ្ហាទាំងនេះនឹងកើតឡើងផងដែរនៅក្នុងករណីនៃអាណត្តិ ពីព្រោះថា ការពិនិត្យមើលស្រដៀងគ្នានេះនឹងត្រូវធ្វើឡើងនៅពេលធ្វើការវិនិច្ឆ័យថា តើអាណត្តិគាហកទទួលរងនូវការខូចខាត "ដើម្បីចាត់ចែងកិច្ចការអាណត្តិ" ឬទេ ។

( មាត្រាពាក់ព័ន្ធ)

មាត្រា ៨២៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា, មាត្រា ៧០២ នៃក្រមរដ្ឋប្បវេណីជប៉ុន, មាត្រា ៦៨៣ និង មាត្រា ៦៨៤ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់, មាត្រា ១៣៧៥ នៃក្រមរដ្ឋប្បវេណីបារាំង

**មាត្រា ៧៣៥.-** សិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រងដោយឈឺឆ្អាល

ក្នុងករណីដែលការគ្រប់គ្រងដោយឈឺឆ្អាលនោះរួមបញ្ចូលនៅក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រង ចំពោះកិច្ចការដែលនៅតែធ្វើបន្ត ក្រោយពេលដែលសាមីខ្លួនបានដឹងអំពីការគ្រប់គ្រងដោយឈឺឆ្អាលនោះរួចហើយ អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារកម្រៃដែលត្រូវបង់ជាទូទៅ ចំពោះការគ្រប់គ្រងដោយឈឺឆ្អាលនោះបាន ។

( កំណត់)

(1) ចំពោះបញ្ហាថា តើត្រូវផ្តល់កម្រៃដល់ការគ្រប់គ្រងដោយឈឺឆ្អាល ឬយ៉ាងណា អាចមានមតិផ្សេងៗគ្នាបានដែរ ។ ប៉ុន្តែ ការគ្រប់គ្រងដោយឈឺឆ្អាល ត្រូវបានធ្វើឡើង តាមសុឆន្ទៈរបស់អ្នកគ្រប់គ្រង ដូចជា សាមគ្គីភាពរវាងគ្នា ការជួយគ្នាទៅវិញទៅមករវាងអ្នកជិតខាង ជាអាទិ៍ ហើយក៏ត្រូវបានធ្វើឡើងដោយមិនផ្អែកលើឆន្ទៈរបស់សាមីខ្លួនទេ ហេតុដូច្នេះ ការគ្រប់គ្រងនោះ គួរតែត្រូវបានចាត់ទុកថាជាសកម្មភាពដោយឥតយកកម្រៃ ហើយសិទ្ធិទាមទារកម្រៃរបស់អ្នកគ្រប់គ្រង ជាគោលការណ៍ គួរតែត្រូវបានបដិសេធ ។

(2) ប៉ុន្តែ បើយោងទៅតាមយុត្តិសាស្ត្រ និង ទស្សនៈរួមរបស់ប្រទេសបារាំង និង ទស្សនៈរួមរបស់ប្រទេសអាល្លឺម៉ង់ និង ប្រទេសជប៉ុន ប្រសិនបើសកម្មភាពគ្រប់គ្រងដោយឈឺឆ្អាលរបស់អ្នកគ្រប់គ្រង ត្រូវបានដាក់បញ្ចូលក្នុងវិជ្ជាជីវៈ ឬ អាជីវកម្មរបស់អ្នកគ្រប់គ្រង អ្នកគ្រប់គ្រងដោយឈឺឆ្អាល អាចទាមទារនូវកម្រៃដែលនឹងត្រូវបានបង់ចំពោះវិជ្ជាជីវៈ ឬ

# ឧបសម្ព័ន្ធទី៤

# ក្រមរដ្ឋប្បវេណីសក្កមចាស់ឆ្នាំ១៩២០

## កថាខ័ណ្ឌទី២
## អំពី ការគ្រប់គ្រងដោយឈឺឆ្អាល

មាត្រា ៨២៥ ៖ ជនណាឥតគេពឹងរក ហើយទទួលគ្រប់គ្រងនូវទ្រព្យសម្បត្តិនៃជនដទៃ ដោយឈឺឆ្អាលពីចិត្តឯង ជននោះត្រូវទទួលគ្រប់គ្រង គ្រាតែដល់ម្ចាស់គេមកគ្រប់គ្រងខ្លួនគេវិញ ។ ជននោះត្រូវយកចិត្តទុកដាក់ចាត់ចែងការបីដូចជាឪពុកដ៏ប្រពៃនៃគ្រកូលគឺថាទុកខ្លួនដូចជាម្ចាស់របស់ពិត១ និងយកចិត្តទុកដាក់នឹងផលប្រយោជន៍ទ្រព្យនោះផង ។

មាត្រា ៨២៦ ៖ កម្មសិទ្ធិករ នៃបេតិកភ័ណ្ឌ ដែលគេបានគ្រប់គ្រងឲ្យដោយត្រឹមត្រូវនោះត្រូវសងទៅអ្នក ដែលគ្រប់គ្រងនោះនូវប្រាក់ដែលគេបានចេញចាយវាយក្នុងការជាចាំបាច់ ឬ ក្នុងការមានប្រយោជន៍ទាំងប៉ុន្មាន១ទៅគេវិញមួយទៀតជននោះត្រូវគិតសោហ៊ុយនៃសេចក្ដីលំបាកក្នុងការថែរក្សានោះឲ្យគេផងទៀត ។

# សេចក្តីផ្តើម

# ជំពូកទី១

## សញ្ញាណទូទៅនៃការគ្រប់គ្រងដោយឈើឆ្កាល

# ជំពូកទី២

## ករណីយកិច្ចរបស់គូភាគី

## ក្នុងការគ្រប់គ្រងដោយឈឺឆ្អាល

# ជំពូកទី៣

## សិទ្ធិរបស់គូភាគី

## ក្នុងការគ្រប់គ្រងដោយឈីផ្លាល

# សេចក្តីសន្និដ្ឋាន

# អនុសាសន៍

# ឯកសារយោង